ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# លទ្ធផលនៃអង្កេតភពផែនដី
# នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩

## (ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ)


រៀបចំដោយ៖

អង្គភាពក្រុមសង្កេតការណ៍ភពផែនដី

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ



ខែ កុម្ភៈ ឆ្នាំ ២០២០

# និមិត្តសញ្ញាសំគាល់
# ក្រុមសង្កេតការណ៍ភពផែនដីកម្ពុជា

( Cambodia GEO )

# បុព្វកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំង ដោយសូមបង្ហាញជូននូវសមិទ្ធិផលថ្មីមួយទៀតដែលសម្រេចបានរបស់ក្រសួងផែនការនៅក្នុងអាណត្តិទី ៦ របស់រាជរដ្ឋាភិបាលកម្ពុជា គឺរបាយការណ៍លទ្ធផលវិភាគទិន្នន័យអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩ ដែលបានសិក្សាទៅលើខេត្ត ៥ ជាប់នឹងបឹងទន្លេសាបរួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ។ អង្កេតភពផែនដី គឺជាអង្កេតលើកទី ១ ដែលបានដឹកនាំអនុវត្តដោយអង្គភាពក្រុមសង្កេតការណ៍ភពផែនដីស្ថិតក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បន្ទាប់ពីប្រទេសកម្ពុជាបានចូលជាសមាជិកទី ១០៤ នៃក្រុមសង្កេតការណ៍ភពផែនដីរួចមក។

អង្កេតភពផែនដីនេះ គឺបានប្រមូលទិន្នន័យនូវសូចនាករចម្បងៗ ស្តីអំពីស្ថានភាពលក្ខណៈប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់គោលដៅនៃខេត្តទាំង ៥ ខាងលើ។ វិធីសាស្ត្រនៃការប្រមូលទិន្នន័យនៃអង្កេតនេះ គឺត្រូវបានធ្វើឡើងតាមរយៈការសម្ភាសន៍ប្រធានភូមិ និងមេគ្រួសារនៅក្នុងតំបន់គោលដៅ ខណៈដែលប្រទេសកម្ពុជាយើងពុំទាន់មានផ្កាយរណប និងពុំមានប្រទេសណាមួយជួយផ្តល់នូវទិន្នន័យតាមរយៈផ្កាយរណបនៅឡើយ។ ថវិកាដែលប្រើប្រាស់នៅក្នុងការធ្វើអង្កេតនេះ គឺបានការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជាតាមរយៈថវិកាកម្មវិធីឆ្នាំ ២០១៩ របស់ក្រសួងផែនការ ។

ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាវជ្រៅជាទីបំផុត ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឲ្យប្រទេសជាតិមានសុខសន្តិភាព និងការឯកភាពជាតិទូទាំងប្រទេសតាមរយៈគោលនយោបាយ «**ឈ្នះឈ្នះ**» ដែលបានផ្តល់ឱកាសដល់ការងារប្រមូលទិន្នន័យនៅតំបន់គោលដៅប្រកបដោយជោគជ័យ។

ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ លោកជំទាវ **ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ឯកឧត្តមបណ្ឌិត **ម៉េង គីមហ៊ី** អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងជាប្រធានអង្គភាពក្រុមសង្កេតការណ៍ភពផែនដី ឯកឧត្តម លោក ប្រធាននាយកដ្ឋាន និងមន្ត្រីពាក់ព័ន្ធទាំងអស់របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ព្រមទាំងមន្ត្រីថ្នាក់ក្រោមជាតិ ដែលរួមមានមន្ត្រីរបស់មន្ទីរផែនការខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ ដែលបានចូលរួមក្នុងការប្រមូលទិន្នន័យតាមតំបន់គោលដៅនៅក្នុងខេត្តទាំង ៥ ខាងលើនេះ។ ខ្ញុំសូមអរគុណចំពោះការខិតខំប្រឹងប្រែងរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី លើការងារទាំងអស់នេះ។

ជាចុងក្រោយ ខ្ញុំសូមអរគុណ និងកោតសរសើរដល់អង្គភាពក្រុមសង្កេតការណ៍ភពផែនដីដែលស្ថិតនៅក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានបំពេញការងារយ៉ាងល្អប្រសើរប្រកបដោយវិជ្ជាជីវៈខ្ពស់ ការប្តេជ្ញាចិត្តមោះមុត និងការលះបង់ដ៏ធំធេង ដើម្បីការងារអង្កេតនេះទទួលបានលទ្ធផលគួរជាទីទុកចិត្តដល់គ្រប់អ្នកប្រើប្រាស់ទិន្នន័យទាំងឡាយ ។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាលកម្ពុជានឹងទទួលបាននូវសារៈប្រយោជន៍ពីលទ្ធផលនៃការធ្វើអង្កេតនេះ ដោយប្រើប្រាស់ទិន្នន័យក្នុងអង្កេតកពផែនដី ដើម្បីរៀបចំធ្វើផែនការ និងរៀបចំគោលនយោបាយទាក់ទងទៅនឹងការតាមដានត្រួតពិនិត្យលក្ខណៈប្រជាសាស្ត្រ ផ្នែកបរិស្ថាន ការពារគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុបន្ថែមពីលើទិន្នន័យដែលបានមកពីប្រភពដទៃទៀតប្រកបដោយប្រសិទ្ធិភាព។ អ្នកប្រើប្រាស់ទិន្នន័យទាំងឡាយ ក៏ដូចជាអ្នកស្រាវជ្រាវ អ្នកវិភាគ និងអង្គការក្រៅរដ្ឋាភិបាលនានា ក៏អាចទទួលបាននូវផលប្រយោជន៍ពីលទ្ធផលនៃអង្កេតនេះផងដែរ ក្នុងការស្វែងយល់អំពីលក្ខណៈប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់គោលដៅខាងលើ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០២០

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន

# អារម្ភកថា

របាយការណ៍លទ្ធផលស្តីពីអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩ នេះបាន ផលិតដោយអង្គភាពក្រុមសង្កេតការណ៍ភពផែនដី ដែលស្ថិតនៅក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួង ផែនការ។ ចាប់តាំងពីប្រទេសកម្ពុជាចូលជាសមាជិកទី១០៤ នៃក្រុមសង្កេតការភពផែនដីនៅឆ្នាំ ២០១៧ មក គម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជានេះ ពុំធ្លាប់ត្រូវបានគេអនុវត្តនៅ ឡើយទេ ទើបតែនៅឆ្នាំ ២០១៩ ប៉ុណ្ណោះ ដែលគម្រោងនេះ ត្រូវបានអនុវត្តដោយទទួលថវិកាឧបត្ថម្ភពី រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងផែនការ។

គោលបំណងចម្បងនៃអង្កេតនេះគឺដើម្បីប្រមូលនូវសូចនាករសំខាន់ៗទាក់ទងនឹងប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ តាមរយៈការសម្ភាសន៍មេភូមិ និងមេគ្រួសារ ជំនួសឲ្យការទទួលបានទិន្នន័យពីផ្កាយរណប និងឧបករណ៍ថតរូបភាពផ្សេងៗ ដែលទទួលពីលើ អាកាស ខណៈដែលបច្ចុប្បន្នការប្រមូលទិន្នន័យពុំទាន់មានលទ្ធភាពធ្វើទៅបាន។ លទ្ធផលនៃអង្កេត ភពផែនដីនៅព្រះរាជាណាចក្រកម្ពុជានេះ រួមមានរបាយការណ៍លទ្ធផលអង្កេតជាឯកសារបោះពុម្ព និងឯកសារជាអេឡិចត្រូនិក ហើយក៏មានដាក់ចូលនៅក្នុងគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួង ផែនការទៀតផង។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** ដែលបានផ្តល់អនុសាសន៍ល្អៗ និងជំរុញលើកទឹកចិត្ត ដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលបានចូលរួមនៅក្នុងការអនុវត្តគម្រោងរហូតទទួលបាន ជោគជ័យ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណជូនចំពោះ **លោកជំទាវ ហង់ លីណា** ប្រតិភូរាជរដ្ឋា ភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានយកចិត្តទុកដាក់ និងបានណែនាំ ដល់មន្ត្រីចុះស្រង់ទិន្នន័យ និងកែច្នៃទិន្នន័យឲ្យមានគុណភាពល្អ និងឯកឧត្តម លោក ប្រធានមន្ទីរ ផែនការខេត្តទាំង ៥ មានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំដែលបាន សហការនៅក្នុងការចុះស្រង់ទិន្នន័យតាមបណ្តាខេត្តពាក់ព័ន្ធខាងលើ។

តាងនាមឲ្យអង្គភាពក្រុមសង្កេតការណ៍ភពផែនដីកម្ពុជា នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ សូមស្វាគមន៍ចំពោះការចង់បាននូវព័ត៌មានបន្ថែមអំពីការធ្វើអង្កេតនេះ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០២០*

**អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ និង ជា**

**ប្រធានអង្គភាពក្រុមសង្កេតការណ៍ភពផែនដីកម្ពុជា**

**បណ្ឌិត ម៉េង គីមហ៊ី**

# មាតិកា


ទំព័រ

និមិត្តសញ្ញាសំគាល់ក្រុមសង្កេតការណ៍ភពផែនដីកម្ពុជា ..... i
បុព្វកថា ..... ii
អារម្ភកថា ..... iv

**ជំពូក ១ សេចក្តីផ្តើម** ..... ១
១.១ សេចក្តីផ្តើម ..... ១
១.២ គោលបំណង ..... ១
១.៣ វិធីសាស្រ្តប្រមូលទិន្នន័យ ..... ២
១.៤ ការកែច្នៃទិន្នន័យ ..... ៣
១.៥ សារៈប្រយោជន៍ ..... ៣

**ជំពូក ២ ស្ថានភាពទូទៅ** ..... ៤
២.១ ប្រជាសាស្រ្ត ..... ៤
២.១.១ និន្នាការចំនួនប្រជាជន ..... ៤
២.១.២ ដង់ស៊ីតេប្រជាជន ..... ៦
២.១.៣ ការបំលាស់ទីកន្លែងរស់នៅ ..... ៧
២.១.៤ ការងារ និងសេដ្ឋកិច្ច ..... ១០
២.២. ទីប្រជុំ គ្រួសារ អាគារ និងលំនៅដ្ឋាន ..... ១២
២.២.១ ទីប្រជុំជន ..... ១២
២.២.២ គ្រួសារ និងអាគារ ..... ១៤
២.២.៣ លំនៅដ្ឋាន ..... ១៦
២.៣ បរិស្ថាន ទឹកស្អាត និងបង្គន់អនាម័យ ..... ១៧
២.៣.១ បរិស្ថាន ..... ១៧
២.៣.២ ទឹកស្អាត ..... ១៨
២.៣.៣ បង្គន់អនាម័យ ..... ២០
២.៤ គ្រោះមហន្តរាយ ..... ២២
២.៥ ការប្រែប្រួលអាកាសធាតុ ..... ២៤
២.៥.១ ស្ថានភាពទឹកភ្លៀង ..... ២៥
២.៥.២ សីតុណ្ហភាព ..... ២៧
២.៥.៣ កម្ពស់ទឹក ..... ២៨

**ជំពូក ៣ ការវិភាគលទ្ធផល** ..... ៣០
៣.១ ព័ត៌មានទូទៅ ..... ៣០
៣.១.១ គ្រួសារ ..... ៣០

៣.១.២ ទំហំគ្រួសារ ........ ៣១
៣.១.៣ ចំណាកស្រុក ........ ៣២
៣.១.៤ ការចូលរួមកម្លាំងពលកម្ម ........ ៣៨
៣.២ បរិស្ថាន ........ ៤០
៣.២.១ បង្គន់អនាម័យ ........ ៤០
៣.២.២ សេវាប្រមូលសំរាម ទីតាំងទុកដាក់សំរាម និង ផលប៉ះពាល់ពីការចាក់សំរាម ........ ៤១
៣.២.៣ ផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្ម ឬ រោងចក្រការបង្ហូរកាកសំណល់ចូលក្នុងទឹក និងការបាញ់សម្លាប់សត្វល្អិត ........ ៤៣
៣.២.៤ ផលប៉ះពាល់ដោយការកាប់បំផ្លាញព្រៃឈើ និងព្រៃលិចទឹក ........ ៤៤
៣.៣ គ្រោះមហន្តរាយ ........ ៤៥
៣.៣.១ ទទួលរងគ្រោះដោយសាររន្ទះបាញ់ ........ ៤៥
៣.៣.២ ទទួលរងគ្រោះដោយសារទឹកជំនន់ ........ ៤៦
៣.៣.៣ ទទួលរងគ្រោះរាំងស្ងួត ........ ៤៧
៣.៣.៤ ទទួលរងគ្រោះដោយសារការបាក់ច្រាំង ទន្លេ ស្ទឹង ព្រែក ........ ៤៨
៣.៤ ការប្រែប្រួលអាកាសធាតុ ........ ៤៩
៣.៤.១ ស្ថានភាពទឹកភ្លៀង ........ ៤៩
៣.៤.២ ស្ថានភាពសីតុណ្ហភាព ........ ៥១
**ជំពូក ៤ បញ្ហាប្រឈម របកគំហើញ ដំណោះស្រាយ និង សន្និដ្ឋាន** ........ ៥២
៤.១ បញ្ហាប្រឈម ........ ៥២
៤.១.១ សម្ភារៈ និង ឧបករណ៍បច្ចេកទេស ........ ៥២
៤.១.២ ទីប្រឹក្សាបច្ចេកទេស និង ថវិកា ........ ៥២
៤.១.៣ សមត្ថភាពមន្ត្រី ........ ៥៣
៤.២ របកគំហើញ ........ ៥៣
៤.២.១ កំណើនប្រជាជន និងការធ្វើចំណាកស្រុក ........ ៥៣
៤.២.២ តំបន់ទីប្រជុំជនមានការកើនឡើង ........ ៥៣
៤.២.៣ បរិស្ថាន ........ ៥៣
៤.២.៤ គ្រោះមហន្តរាយ ........ ៥៤
៤.២.៥ ការប្រែប្រួលអាកាសធាតុ ........ ៥៤
៤.៣ ដំណោះស្រាយ ........ ៥៤
៤.៤ សន្និដ្ឋាន ........ ៥៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូក ១
# សេចក្តីផ្តើម

## ១.១ សេចក្តីផ្តើម

ប្រទេសកម្ពុជា គឺត្រូវបាននាយកលេខាធិការនៃលេខាធិការដ្ឋាន ក្រុមសង្កេតការណ៍ភពផែនដី ប្រកាសជាផ្លូវការចូលជាសមាជិកទី ១០៤ នៃក្រុមសង្កេតការណ៍ភពផែនដីនៅក្នុងអំឡុងពេលកិច្ចប្រជុំពិភាក្សាលើកទី១៤ ដែលបានប្រារព្ធធ្វើពីថ្ងៃទី ២៥ ដល់ ២៦ ខែ តុលា ឆ្នាំ២០១៧ នៅទីក្រុងវ៉ាស៊ីនតោនសហរដ្ឋអាមេរិក ដែលមានវត្តមាន **ឯកឧត្តម ជុំ ប៊ុនរ៉ុង** ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនសហរដ្ឋអាមេរិក តំណាងឲ្យប្រទេសកម្ពុជា ព្រមទាំងមានការចូលរួមពីលេខាទី១របស់ស្ថានទូត និងមន្ត្រីជាន់ខ្ពស់របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការតាមរយៈសំណើរបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០១៧។ បន្ទាប់ពីបានចូលជាសមាជិកក្រុមសង្កេតការណ៍ភពផែនដីជាផ្លូវការរួចមក អង្គភាពក្រុមសង្កេតការណ៍ភពផែនដីស្ថិតក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវបានបង្កើតឡើង ដើម្បីងាយស្រួលធ្វើកិច្ចការងារផ្សេងៗជាមួយអគ្គលេខាធិការដ្ឋានក្រុមសង្កេតភពផែនដី ដែលមានទីស្នាក់ការកណ្តាលនៅទីក្រុងហ្សឺណែវប្រទេសស្វីស ។ ការងារសំខាន់របស់ប្រទេសជាសមាជិកក្រុមសង្កេតការភពផែនដី គឺសិក្សាស្រាវជ្រាវ និងវិភាគទិន្នន័យ ដែលបានមកពីផ្កាយរណប ឬ ឧបករណ៍ផ្សេងៗ ដែលថតរូបភាពពីលើអាកាស សម្រាប់ធ្វើការតាមដានត្រួតពិនិត្យបរិស្ថាន គ្រោះមហន្តរាយ និង ការប្រែប្រួលអាកាសធាតុ។ ដោយឡែក ចំពោះប្រទេសកម្ពុជាពេលបច្ចុប្បន្ននេះ ពុំមានផ្កាយរណប ឬ ឧបករណ៍ថតពីលើអាកាសទេ ហេតុដូច្នេះជំនួសការប្រមូលទិន្នន័យត្រូវធ្វើតាមរយៈការសម្ភាសន៍មេភូមិ និង មេគ្រួសារដែលរស់នៅក្នុងតំបន់គោលដៅនោះវិញ។ សម្រាប់ការអនុវត្តការងារជំហានទី ១ អង្គភាពក្រុមសង្កេតការភពផែនដី បានរៀបចំគម្រោងសកម្មភាពការងារដែលបានផ្តោតទៅលើខេត្ត៥នៅជាប់បឹងទន្លេសាបរួមមានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ ដោយប្រើប្រាស់ថវិការាជរដ្ឋាភិបាលកម្ពុជាដែលមានចំនួនកំណត់។

## ១.២ គោលបំណង

គោលបំណងសំខាន់នៃការអនុវត្តគម្រោងនេះ គឺការកសាងប្រព័ន្ធទិន្នន័យស្ថិតិទាក់ទងបរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុសម្រាប់ខេត្ត ៥ ជាប់បឹងទន្លេសាបរួមមានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និង កំពង់ធំ ដើម្បីចូលរួមតាមដានលើការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## ១.៣ វិធីសាស្ត្រប្រមូលទិន្នន័យ

ទិន្នន័យសម្រាប់ធ្វើការវិភាគនេះ គឺបានមកពីការប្រមូលទិន្នន័យពីរប្រភេទ គឺទិន្នន័យទី១ និង ទិន្នន័យទី២។ វិធីសាស្ត្រនៃការប្រមូលទិន្នន័យទី១ គឺត្រូវបានប្រមូលតាមរយៈការធ្វើសម្ភាសន៍មេភូមិ និងមេគ្រួសារនៅក្នុងភូមិគោលដៅនៃខេត្តទាំង ៥ ដែលជាប់បឹងទន្លេសាប។ កម្រងសំណួរសម្រាប់សម្ភាសន៍មានពីរ គឺកម្រងសំណួរសម្រាប់សម្ភាសន៍មេភូមិ និងកម្រងសំណួរសម្រាប់សម្ភាសន៍មេគ្រួសារ ។ ចំនួនភូមិគោលដៅ ១៥ភូមិ និង ចំនួនមេគ្រួសារ ១.៥០០ នាក់ ស្ថិតនៅក្នុងខេត្ត៥ ជាប់បឹងទន្លេសាបគឺត្រូវបានធ្វើសម្ភាសន៍។ ទិន្នន័យទី ២ គឺត្រូវបានប្រមូលពីក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ដែលបានផលិតចេញជារបាយការណ៍ផ្សេងៗ។

តារាង ១.១ បង្ហាញពីបញ្ជីភូមិគោលដៅសម្រាប់ធ្វើការសម្ភាសន៍ស្រង់ទិន្នន័យ នៅក្នុងខេត្ត ៥ ជាប់បឹងទន្លេសាបរួមមានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងកំពង់ធំ។

**តារាង ១.១ បញ្ជីភូមិសម្រាប់សម្ភាសន៍**

| ល.រ | ខេត្ត | ស្រុក | សង្កាត់/ឃុំ | ភូមិ | ចំនួនគ្រួសារ | ចំនួនគ្រួសារត្រូវសម្ភាសន៍ |
|---|---|---|---|---|---|---|
| ១ | កំពង់ឆ្នាំង | ក្រុងកំពង់ឆ្នាំង | ផ្សារឆ្នាំង | ចុងកោះ | 403 | 100 |
| | | កំពង់លែង | កំពង់ហៅ | ត្នោតរលំ | 342 | 100 |
| | | បរិបូរ | ខុនរ៉ង | ត្រពាំងពោធិ៍ | 208 | 100 |
| ២ | ពោធិ៍សាត់ | បាកាន | មេទឹក | សំរោងព្រៃខៀវ | 198 | 100 |
| | | បាកាន | មេទឹក | ចិន្តាយ | 383 | 100 |
| | | បាកាន | មេទឹក | អូរព្រាល | 236 | 100 |
| ៣ | បាត់ដំបង | ឯកភ្នំ | ព្រែកនរិន្ទ | ព្រែកក្រូច | 315 | 100 |
| | | ឯកភ្នំ | ព្រែកហ្លួង | ព្រែកហ្លួង | 519 | 100 |
| | | ឯកភ្នំ | ព្រែកហ្លួង | ស្ពឺលើ | 433 | 100 |
| ៤ | សៀមរាប | សៀមរាប | ចុងឃ្នៀស | ទី៦ | 204 | 100 |
| | | ប្រាសាទបាគង | កំពង់ភ្លុក | គោកក្ដុល | 313 | 100 |
| | | ពួក | កែវពណ៌ | ស្វាយចេក | 195 | 100 |
| ៥ | កំពង់ធំ | ស្រុកកំពង់ស្វាយ | កំពង់គោ | កំពង់គោលើ | 292 | 100 |
| | | ស្រុកកំពង់ស្វាយ | កំពង់គោ | កំពង់គោក្រោម | 258 | 100 |
| | | ស្រុកកំពង់ស្វាយ | កំពង់គោ | ខ្សាច់ដំរីស | 508 | 100 |
| **សរុប** | | | | | **4,807** | **1,500** |

## ១.៤ ការកែច្នៃទិន្នន័យ

ទិន្នន័យដែលបានមកពីការធ្វើសម្ភាសន៍តាមរយៈមេភូមិ និង មេគ្រួសារនៅតាមភូមិគោលដៅនៅក្នុងខេត្តទាំង ៥ ដែលជាប់បឹងទន្លេសាប គឺត្រូវបានវាយបញ្ចូលទៅក្នុងកុំព្យូទ័រ ដោយប្រើប្រាស់កម្មវិធី CSPro 7.3 និងការពិនិត្យកំហុស និងការផលិតជាតារាងសម្រាប់ធ្វើការវិភាគក៏បានប្រើប្រាស់កម្មវិធី CSPro 7.3 នេះផងដែរ ។ ចំពោះកម្មវិធី Microsoft Excel គឺត្រូវបានប្រើប្រាស់សម្រាប់ការធ្វើក្រាហ្វិក និង កម្មវិធី Microsoft Word គឺសម្រាប់សរសេររបាយការណ៍វិភាគទិន្នន័យ។

## ១.៥ សារៈប្រយោជន៍

របាយការណ៍វិភាគទិន្នន័យនេះ គឺមានសារៈសំខាន់ដល់អ្នកសិក្សាស្រាវជ្រាវ អ្នកធ្វើផែនការ និងអ្នករៀបចំគោលនយោបាយផ្សេងៗ ជាពិសេសរាជរដ្ឋាភិបាលមានទិន្នន័យបន្ថែមទៀតសម្រាប់រៀបចំគោលនយោបាយទាក់ទងទៅនឹងការត្រួតពិនិត្យតាមដានលើផ្នែកបរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុតាមតំបន់នីមួយៗនៅក្នុងប្រទេសកម្ពុជា និងមានវិធានការបង្ការនូវហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងដោយសារគ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុជាដើម។

# ជំពូក ២
# ស្ថានភាពទូទៅ

## ២.១ ប្រជាសាស្ត្រ
### ២.១.១ និន្នាការចំនួនប្រជាជន

ចំនួនប្រជាជនសរុបនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានបង្ហាញតាមរយៈការធ្វើជំរឿនប្រជាជនឆ្នាំ ១៩៦២ មានចំនួន៥,៧ លាននាក់ បានកើនឡើងដល់ចំនួន ១១,៤ លាននាក់ ផ្អែកតាមការធ្វើជំរឿនប្រជាជនឆ្នាំ ១៩៩៨ រយៈពេល៣៦ឆ្នាំនេះប្រជាជនកម្ពុជា បានកើនឡើងជាង២ដងស្មើនឹងចំនួន៧,៧ លាននាក់ ។ ចំនួនប្រជាជនក្នុងរយៈពេល១០ឆ្នាំ គិតចាប់ពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០៨ មានការកើនឡើងប្រហែលចំនួន ២លាននាក់ (៩,៥%) ហើយក្នុងរយៈពេល ១១ឆ្នាំ គិតចាប់ពីឆ្នាំ ២០០៨ ដល់ឆ្នាំ២០១៩ កើនឡើងចំនួន ១,៩លាននាក់ (១៤,១%) នឹងត្រូវបានគេរំពឹងទុកថានៅឆ្នាំ ២០៣០ ចំនួនប្រជាជនកម្ពុជាអាចកើនដល់ ១៨,៤លាននាក់។ ក្រាហ្វិក២.១ បង្ហាញអំពីនិន្នាការចំនួនប្រជាជនសរុប ទូទាំងប្រទេសផ្អែកតាមទិន្នន័យអង្កេត និង ជំរឿនប្រជាជនតាមបណ្តាឆ្នាំ។

**ក្រាហ្វិក ២.១ និន្នាការចំនួនប្រជាជនសរុបទូទាំងប្រទេស**




*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩*
*២. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*
*៣. ទិន្នន័យឆ្នាំ ២០១៧ ផ្អែកលើទិន្នន័យមូលដ្ឋានរបស់មន្ទីរផែនការខេត្តទាំង ៥*
*៤. ទិន្នន័យឆ្នាំ ២០២៥ និង ២០៣០ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០១១*

តំបន់បឹងទន្លេសាបមានចំនួន ៨ ខេត្ត គឺមានខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង ពោធិ៍សាត់ ប៉ៃលិន សៀមរាប ឧត្តរមានជ័យ និងខេត្តកំពង់ធំ ដែលមានចំនួនប្រជាជនសរុបនៅឆ្នាំ១៩៩៨ គឺមានចំនួន ៣,៥ លាននាក់ ស្មើនឹង ៣០,២ ភាគរយ ធៀបទៅនឹងចំនួនប្រជាជនទូទាំងប្រទេស ខណៈដែលខេត្ត ៥ ដែលជាប់បឹងទន្លេសាប រួមមាន ខេត្តបាត់ដំបង កំពង់ឆ្នាំង ពោធិ៍សាត់ សៀមរាប និងខេត្តកំពង់ធំមានចំនួនប្រជាជន ២,៨ លាននាក់ ស្មើនឹង ២៤,៨ ភាគរយធៀបនឹងទូទាំងប្រទេសនៅក្នុងឆ្នាំ ១៩៩៨ ដូចគ្នា។ នៅក្នុងឆ្នាំ ២០០៨ ចំនួនប្រជាជននៅក្នុងតំបន់បឹងទន្លេសាប ដែលមានខេត្តទាំង៨ ខាងលើ មានចំនួនប្រជាជនបានកើនឡើងដល់ ៤,៤ លាននាក់ ស្មើនឹង ៣២,៥ ភាគរយបើធៀបនឹងប្រជាជនទូទាំងប្រទេស ខណៈដែលខេត្ត៥ដែលជាប់បឹងទន្លេសាប គឺមានចំនួនប្រជាជនសរុប ៣,៤លាននាក់ ស្មើនឹង ២៥,៥ភាគរយ ប្រៀបធៀបនឹងចំនួនប្រជាជនទូទាំងប្រទេស នៅក្នុងឆ្នាំដូចគ្នា ។ នៅក្នុងឆ្នាំ ២០១៩ ចំនួនប្រជាជននៅក្នុងតំបន់បឹងទន្លេសាប ដែលមានខេត្តទាំង ៨ ខាងលើ មានចំនួនកើនឡើងដល់ ៥,៣ លាននាក់ ស្មើនឹង ៣៣,៧ ភាគរយធៀបនឹងប្រជាជនទូទាំងប្រទេស ខណៈដែលខេត្ត៥ជាប់បឹងទន្លេសាបមានចំនួនប្រជាជនសរុប ៤,០ លាននាក់ ស្មើនឹង ២៥,៩ ភាគរយ ហើយតំបន់បឹងទន្លេសាបនឹងអាចកើនឡើងដល់ ៦,២ លាននាក់ ស្មើនឹង ៣៥,១ភាគរយ និងខេត្តទាំង ៥ អាចកើន ៤,២ លាននាក់ ស្មើនឹង ២៦,២ភាគរយ នៅក្នុងឆ្នាំ ២០៣០ បើធៀបនឹងចំនួនប្រជាជនសរុបទូទាំងប្រទេស។

**តារាង ២.១ ចំនួនប្រជាជនសរុប ពីឆ្នាំ ១៩៩៨ ដល់ ២០៣០ គិតជាពាន់នាក់**

| ឆ្នាំ | កំពង់ឆ្នាំង | ពោធិ៍សាត់ | បាត់ដំបង | សៀមរាប | កំពង់ធំ | សរុប | តំបន់បឹងទន្លេសាប | កម្ពុជា |
|---|---|---|---|---|---|---|---|---|
| 1998 | 418 | 360 | 793 | 696 | 569 | 2,836 | 3,460 | 11,438 |
| 2004 | 532 | 456 | 972 | 755 | 607 | 3,322 | 4,172 | 12,824 |
| 2008 | 472 | 397 | 1,025 | 896 | 631 | 3,423 | 4,357 | 13,396 |
| 2013 | 523 | 436 | 1,121 | 923 | 690 | 3,693 | 4,720 | 14,677 |
| 2017 | 551 | 491 | 1,268 | 1,067 | 798 | 4,175 | 5,266 | 15,685 |
| 2019 | 872 | 412 | 987 | 1,007 | 677 | 3,955 | 5,148 | 15,288 |
| 2025 | 607 | 515 | 1,431 | 1,320 | 716 | 4,588 | 5,400 | 17,519 |
| 2030 | 629 | 553 | 1,519 | 1,415 | 724 | 4,840 | 6,153 | 18,391 |

*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩*
*២. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*
*៣. ទិន្នន័យឆ្នាំ ២០១៧ ផ្អែកលើទិន្នន័យមូលដ្ឋានរបស់មន្ទីរផែនការខេត្តទាំង ៥*
*៤. ទិន្នន័យឆ្នាំ ២០២៥ និង ២០៣០ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០១១*

### ក្រាហ្វិក ២.២ និន្នាការចំនួនប្រជាជនខេត្តទាំង ៥ ជាប់បឹងទន្លេសាប




*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩*
*២. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*
*៣. ទិន្នន័យឆ្នាំ ២០១៧ ផ្អែកលើទិន្នន័យមូលដ្ឋានរបស់មន្ទីរផែនការខេត្តទាំង ៥*
*៤. ទិន្នន័យឆ្នាំ ២០២៥ និង ២០៣០ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០១១*

## ២.១.២ ដង់ស៊ីតេប្រជាជន

ដង់ស៊ីតេប្រជាជនជាសូចនាករមួយយ៉ាងសំខាន់សម្រាប់ពិនិត្យមើលរបាយប្រជាជនតាមតំបន់ រាជធានី ខេត្ត ។ ដង់ស៊ីតេចំនួនប្រជាជនទូទាំងប្រទេសនៅឆ្នាំ ២០០៨ មានដង់ស៊ីតេចំនួន ៧៥នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ហើយបានកើនឡើង ៨៦នាក់ក្នុងមួយគីឡូម៉ែត្រការ៉េនៅឆ្នាំ២០១៩។ ចំណែកឯនៅក្នុងតំបន់បឹងទន្លេសាបមានដង់ស៊ីតេចំនួន ៥៧ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េក្នុងឆ្នាំ ២០០៨ និង បានកើនឡើង ៦២នាក់ក្នុងមួយគីឡូម៉ែត្រការ៉េក្នុងឆ្នាំ ២០១៩។ ចំណែកឯខេត្តទាំង ៥ ជាប់បឹងទន្លេសាបមានដង់ស៊ីតេចំនួន ៦៣ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ហើយបានកើនឡើងដល់ ៧៣នាក់ក្នុងមួយគីឡូម៉ែត្រការ៉េនៅក្នុងឆ្នាំ ២០១៩។

### រូបភាព ២.៣ ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ ២០១៩




ប្រភព: លទ្ធផលបណ្តោះអាសន្ននៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩

## ២.១.៣ ការបំលាស់ទីកន្លែងរស់នៅ

ការផ្លាស់ប្តូរទីកន្លែងរស់នៅ ឬ ការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនកម្ពុជា គឺត្រូវបានកំណត់ជាដំណើរការនៃការផ្លាស់ប្តូរកន្លែងរស់នៅ ពីទីតាំងភូមិសាស្ត្រមួយទៅទីតាំងភូមិសាស្ត្រមួយទៀត។ យោងតាមអនុសាសន៍របស់អង្គការសហប្រជាជាតិ បានឲ្យគ្រប់ប្រទេសទាំងអស់លើពិភពលោកបញ្ចូលសូចនាករនេះទៅក្នុងតារាងបញ្ជីសំណួរនៃការធ្វើជំរឿនប្រជាជន ដើម្បីសិក្សាអំពីចរិកលក្ខណៈនៃការផ្លាសប្តូរលំនៅដ្ឋាន។ ជាក់ស្តែងផងដែរ រាជរដ្ឋាភិបាលកម្ពុជាមានទិន្នន័យសម្រាប់ការរៀបចំគោលនយោបាយជាតិទាក់ទងការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងរកវិធីសាស្ត្រណាទប់ស្កាត់ការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជន តាមរយៈការអភិវឌ្ឍ និងបង្កើតការងារនៅក្នុងស្រុក ឬ នៅទីតាំងជិតលំនៅដ្ឋានរបស់ពួកគាត់តែម្តង ។ នៅឆ្នាំ ១៩៩៨ ប្រជាជនទូទាំងប្រទេសមានការផ្លាស់ប្តូរលំនៅដ្ឋានមានចំនួន ៣១ភាគរយ ហើយបានកើនឡើង ៣៥ភាគរយនៅឆ្នាំ ២០០៤ ប៉ុន្តែនៅឆ្នាំ ២០០៨ បានធ្លាក់ចុះមកត្រឹម ២៦,៥ភាគរយ និងបានកើនឡើងវិញនៅឆ្នាំ ២០១៣ មានចំនួន ២៨,៩ភាគរយ។

### រូបភាព ២.៤ ការផ្លាស់ប្តូរទីលំនៅពីមុនទូទាំងប្រទេស




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- របាយការណ៍ទូទៅនៃការធ្វើអង្កេតប្រជាសាស្ត្រកម្ពុជា អង្កេតចន្លោះជំរឿន ឆ្នាំ ២០០៤
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជាសាស្ត្រកម្ពុជាឆ្នាំ ២០១៣
- លទ្ធផលបណ្តោះអាសន្ននៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩

ស្ថានភាពនៃការផ្លាស់ប្តូរទីលំនៅដ្ឋានរបស់ប្រជាជនកម្ពុជា នៅតាមតំបន់ទីប្រជុំជន គឺមានចំនួនច្រើនជាងតំបន់ជនបទទាំងនៅឆ្នាំ ២០០៨ និង ២០១៣ ។ នៅឆ្នាំ ២០០៨ ប្រជាជនដែលបានផ្លាស់ប្តូរលំនៅដ្ឋានមានចំនួន ៥៩,៧ភាគរយ ហើយបានថយចុះនៅឆ្នាំ ២០១៣ ដែលមានចំនួន ៤៩,៤ភាគរយ ខណៈដែលតំបន់ជនបទនៅឆ្នាំ ២០០៨ មានចំនួន ១៨,៩ ភាគរយ ហើយបានកើនឡើងដល់ ២៣,៣ ភាគរយ នៅឆ្នាំ ២០១៣ ។

## រូបភាព ២.៥ ការផ្លាស់ប្តូរទីលំនៅតាមតំបន់




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ ២០១៣

នៅក្នុងឆ្នាំ ២០០៨ និង ២០១៣ មូលហេតុចម្បងនៃការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជនមានចំនួនច្រើនជាងគេក្នុងចំណោមមូលហេតុដទៃទៀតនៃការផ្លាស់ប្តូរលំនៅដ្ឋាន។ នៅឆ្នាំ ២០០៨ មូលហេតុគ្រួសារផ្លាស់ប្តូរលំនៅដ្ឋានមានចំនួន ៣៧,៥ ភាគរយ និងបានកើនឡើងដល់ ៤២,២ភាគរយ នៅឆ្នាំ ២០១៣ ។ ការផ្លាស់ប្តូរនេះ ប្រហែលគ្រួសារទាំងនោះគិតថាការទៅរស់នៅកន្លែងថ្មីមានលក្ខណៈសេដ្ឋកិច្ចល្អប្រសើរជាងកន្លែងចាស់ ដែលពួកគាត់រស់នៅ ហើយពួកគាត់បានលក់ផ្ទះសម្បែង និងដីធ្លីដែលជាកម្មសិទ្ធិរបស់ពួកគាត់ពីមុន។ មូលហេតុរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ ២០១៣ មានចំនួនច្រើនជាង ឆ្នាំ ២០០៨ ចំនួន ៧,២ ភាគរយ ហើយមូលហេតុអសន្តិសុខ និង កូនកំព្រាក៏មានចំនួនច្រើនជាងឆ្នាំ ២០០៨ ដែរ ខណៈដែល នៅក្នុងឆ្នាំ ២០១៣ ភាគរយនៃប្តូរទីកន្លែងការងារ ស្វែងរកការងារ និងការសិក្សាមានចំនួនតិចជាង ឆ្នាំ ២០០៨ ។ ចំពោះខេត្តទាំង ៥ ជាប់បឹងទន្លេសាបគឺមានស្ថានភាពប្រហាក់ប្រហែលនៅជនបទដែរ។

## រូបភាព ២.៦ មូលហេតុនៃការផ្លាស់ប្តូរទីលំនៅ




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ ២០១៣

## ២.១.៤ ការងារ និងសេដ្ឋកិច្ច

ប្រជាជនកម្ពុជាអ្នកមានការងារធ្វើសម្រាប់ទូទាំងប្រទេសមានចំនួនលើសពី ៩០ ភាគរយ ចាប់តាំងពីឆ្នាំ ១៩៩៨ ដល់ ២០១៣ ។ នៅក្នុងឆ្នាំ ១៩៩៨ អ្នកមានការងារធ្វើមានចំនួន ៩៤,៧ ភាគរយ នៅឆ្នាំ២០០៨ បានកើនឡើងដល់ ៩៨,៣ ភាគរយ និងបានថយចុះបន្តិចនៅឆ្នាំ ២០១៣ មកត្រឹម ៩៧,៦ ភាគរយ ។ អត្រាអ្នកគ្មានការងារធ្វើនៅឆ្នាំ ១៩៩៨ មានចំនួន ៥,៣៤ ភាគរយ ច្រើនជាងឆ្នាំ ២០០៨ ដែលមានចំនួន ១,៧ ភាគរយ និងឆ្នាំ ២០១៣ មានចំនួន ២,៤ ភាគរយ ។ រូបភាព ២.៧ ខាងក្រោមបង្ហាញអំពីអត្រាអ្នកគ្មានការងារធ្វើពីឆ្នាំ ១៩៩៨ ដល់ ២០១៣ ។

### រូបភាព ២.៧ អត្រាអ្នកគ្មានការងារធ្វើ




ប្រភពៈ - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ ២០១៣

អត្រាអ្នកមានការងារធ្វើ ត្រូវបានបែងចែកតាមវិស័យសេដ្ឋកិច្ចចម្បងៗរួមមាន វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម។ នៅក្នុងឆ្នាំ១៩៩៨ អត្រាចូលរួមកម្លាំងពលកម្មក្នុងវិស័យកសិកម្មមានចំនួន ៧៧,៥ ភាគរយ ហើយបានថយចុះមកត្រឹម ៧២,៣ ភាគរយ នៅឆ្នាំ ២០០៨ និងបន្តធ្លាក់ចុះមានចំនួន៦៤,៣ភាគរយ នៅឆ្នាំ២០១៣ ខណៈដែលអត្រានៃការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មមានការកើនឡើង។ នៅក្នុងឆ្នាំ ២០០៨ អត្រានៃការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យឧស្សាហកម្មមានចំនួន ៨,៥ ភាគរយ និង វិស័យសេវាកម្មមានចំនួន ១៩,២ ភាគរយ និងនៅឆ្នាំ ២០១៣ អត្រាចូលរួមកម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្មមានចំនួន ១១,៥ ភាគរយ និង វិស័យសេវាកម្មមានចំនួន ២៣,៨ ភាគរយ ។

រូបភាព ២.៨ ការបែងចែកភាគរយអ្នកមានការងារធ្វើតាមវិស័យសេដ្ឋកិច្ច




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ ២០១៣

## ២.២ ទីប្រជុំជន គ្រួសារ អគារ និងលំនៅដ្ឋាន

### ២.២.១ ទីប្រជុំជន

ការកើនឡើងនូវនគរូបនីយកម្ម នៅលើពិភពលោកបានធ្វើឲ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងសម្រាប់ពិភពលោកនិងតាមប្រទេសនីមួយៗ ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានកែសម្រួលតំបន់រដ្ឋបាលញឹកញាប់ចាប់តាំងពីឆ្នាំ ១៩៩៨ មកទល់បច្ចុប្បន្ន។ ការកែសម្រួលតំបន់រដ្ឋបាលនេះ ក៏ជាកត្តាមួយដែលធ្វើឲ្យមានការកើនឡើងនូវតំបន់ទីប្រជុំជន ដោយសារតំបន់មួយចំនួនក្លាយជាក្រុងជាគោលដៅអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគ្រប់ផ្នែក និងលំនៅដ្ឋានទៀតផង។ ដូច្នេះផ្ទៃដីស្រែមួយចំនួនត្រូវបានបង្វែរមុខងារពីដីកសិកម្ម ទៅជាដីសម្រាប់ការសាងសង់នៅពេលអនាគត ។ កន្លងមកការកំណត់តំបន់ទីប្រជុំជនពុំមាននិយមន័យច្បាស់លាស់នៅឡើយទេ ។ នៅឆ្នាំ ១៩៩៨ ទីប្រឹក្សាជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨ បានកំណត់ស្រុកដែលស្ថិតក្នុងទីរួមខេត្តជាទីប្រជុំជន ។ នៅឆ្នាំ ២០០៤ ជំនាញការរបស់

មូលនិធិអង្គការសហប្រជាជាតិសម្រាប់ប្រជាជននៅឆ្នាំ ២០០៤ បានកំណត់និយមន័យទីប្រជុំជន ដោយកំណត់ ៣ លក្ខខណ្ឌគឺ៖

១) ចំនួនប្រជាជនទាបបំផុតចាប់ពី ២.០០០ នាក់ឡើង ក្នុងមួយឃុំ

២) ដង់ស៊ីតេប្រជាជនក្នុងមួយគីឡូម៉ែត្រការ៉េចាប់ពី ២០០នាក់ ឡើង

៣) ភាគរយបុរសធ្វើការក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ

នៅឆ្នាំ ២០១១ និយមន័យលក្ខខណ្ឌទីប្រជុំជនបានកែសម្រួលនៅលក្ខខណ្ឌទី ៣ គឺ ភាគរយបុរសធ្វើការក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ ទៅជាភាគរយប្រជាជនទាំងពីរភេទធ្វើការនៅក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ ហើយលក្ខខណ្ឌទី ១ និងទី ២ គឺរក្សានៅដដែល។ លក្ខខណ្ឌទាំងនោះគឺ៖

១) ចំនួនប្រជាជនទាបបំផុតចាប់ពី ២.០០០ នាក់ឡើង ក្នុងមួយឃុំ

២) ដង់ស៊ីតេប្រជាជនក្នុងមួយគីឡូម៉ែត្រការ៉េចាប់ពី ២០០នាក់ ឡើង

៣) ភាគរយចំនួនប្រជាជនទាំងពីរភេទធ្វើការក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ

នៅក្នុងរូបភាព ២.៩ បង្ហាញអំពីភាគរយចំនួនប្រជជានរស់នៅតំបន់ទីប្រជុំជន ដែលមាននិន្នាការកើនឡើងជាលំដាប់។ នៅក្នុងឆ្នាំ ១៩៩៨ ចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំផ្អែកលើការកំណត់ស្រុកក្នុងទីរួមខេត្តជាតំបន់ទីប្រជុំជនមានចំនួន ១៥,៧ភាគរយ ហើយនៅឆ្នាំ២០០៤ ការកំណត់និយមន័យទីប្រជុំថ្មីដោយប្រើប្រាស់ទិន្នន័យជំរឿនឆ្នាំ ១៩៩៨ ដដែលគឺមានការកើនចំនួន ២ ភាគរយ។ លទ្ធផលនៃការធ្វើជំរឿនៅឆ្នាំ ២០០៨ បានអនុវត្តន៍និយមន័យទីប្រជុំជនឆ្នាំ ២០០៤ គឺចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជនមានចំនួន ១៩,៥ ភាគរយ និងផ្អែកលើនិយមន័យទីប្រជុំជនថ្មីឆ្នាំ ២០១១ ចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជនមានការកើនឡើងដល់ ២៧,១ ភាគរយ ។ ភាគរយចំនួនប្រជាជនដែលរស់នៅតំបន់ទីប្រជុំជននៅឆ្នាំ ២០១៨ តាមការប៉ាន់ស្មានមានចំនួន ៣៣,៦ ភាគរយ នឹងនៅឆ្នាំ ២០៣០ អាចកើនឡើងរហូតដល់ ៤៣ ភាគរយ ។ ទោះបីជានិយមន័យមានការខុសគ្នាយ៉ាងណាក៏ដោយ ជាក់ស្តែងប្រជាជនដែលរស់នៅតំបន់ទីប្រជុំជនមានការកើនឡើង ដោយសារកត្តាការកើនឡើងលំនៅដ្ឋានថ្មីៗ ការស្វែងរកការងារដែលពួកគាត់គិតថាមានលក្ខណៈប្រសើរជាងកន្លែងរស់នៅចាស់ និងកត្តាសេដ្ឋកិច្ចផ្សេងៗ។

### រូបភាព ២.៩ ភាគរយចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជន




ប្រភព៖ ការកំណត់ចំណាត់ថ្នាក់ទីប្រជុំជនឡើងវិញ ឆ្នាំ ២០១១

## ២.២.២ គ្រួសារ និងអគារ

សូចនាករចំនួនគ្រួសារ គឺជាសូចនាករមួយមានសារៈសំខាន់ណាស់ទាក់ទងទៅនឹងការផ្តល់សេវាផ្សេងៗដូចជាអគ្គិសនី ទឹកស្អាត បង្គន់អនាម័យ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។ ចំនួនគ្រួសារសរុបនៅឆ្នាំ ១៩៩៨ មានចំនួន ២,១៦ លានគ្រួសារ ហើយបានកើនឡើងរហូតដល់ ៣,៣៤ លានគ្រួសារ នៅឆ្នាំ ២០១៩ សម្រាប់ទូទាំងប្រទេស។ តំបន់ដែលនៅជាប់បឹងទន្លេសាបនៅឆ្នាំ ១៩៩៨ មានចំនួនគ្រួសារ ៦៦១.៩៦២ និងចំនួនអាគារប្រមាណ ៥៩៨.៤៤៧ ហើយចំនួនអគារគិតជាមធ្យមមានប្រមាណ ៩០ភាគរយ នៃចំនួនគ្រួសារ។ នៅក្នុងឆ្នាំ ១៩៩៨ មានអាគារប្រមាណ ខណៈដែលខេត្ត ៥ ជាប់បឹងទន្លេសាបមានគ្រួសារចំនួន ៥៣៣.៤៤២ និងអគារប្រមាណ ៤៨២.២៥៨ ។ នៅក្នុងឆ្នាំ ២០១៩ តំបន់បឹងទន្លេសាបមានចំនួនគ្រួសារ ១.០៦៧.៤៦៩ និងមានចំនួនអាគារប្រមាណ ៩៦៥.០៤៥ ខណៈដែលខេត្តទាំង ៥ ជាប់បឹងទន្លេសាបមានចំនួនគ្រួសារ ៨១៦.៧៧៩ និងមានចំនួនអាគារប្រមាណ ៧៣៨.៤០៩ ។

## តារាង ២.២ ចំនួនគ្រួសារ និង អាគារ

| ឆ្នាំ | ចំនួនគ្រួសារ | | | ចំនួនអាគារ | | |
|---|---|---|---|---|---|---|
| | កម្ពុជា | តំបន់បឹងទន្លេសាប | ខេត្ត៥ជាប់បឹងទន្លេសាប | កម្ពុជា | តំបន់បឹងទន្លេសាប | ខេត្ត៥ជាប់បឹងទន្លេសាប |
| 1998 | 2,162,086 | 661,962 | 533,442 | 1,954,634 | 598,447 | 482,258 |
| 2004 | 2,530,000 | 818,039 | 651,373 | 2,287,246 | 739,548 | 588,873 |
| 2008 | 2,817,637 | 905,039 | 707,547 | 2,637,654 | 818,201 | 639,658 |
| 2013 | 3,163,226 | 1,155,203 | 802,853 | 2,758,261 | 1,044,361 | 725,820 |
| 2019 | 3,341,770 | 1,067,469 | 816,779 | 3,021,127 | 965,045 | 738,409 |

ប្រភពៈ - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- របាយការណ៍ទូទៅនៃការធ្វើអង្កេតប្រជាពលរដ្ឋកម្ពុជា អង្កេតចន្លោះជំរឿន ឆ្នាំ ២០០៤
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជាពលរដ្ឋកម្ពុជាឆ្នាំ ២០១៣
- លទ្ធផលបណ្ដោះអាសន្នជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩

នៅក្នុងឆ្នាំ ២០១៣ អាគារប្រភេទអចិន្ត្រៃយ៍មានចំនួនប្រហែល ៧៣ភាគរយ កើនឡើងជាងឆ្នាំ ២០០៨ ចំនួន ១៦ ភាគរយ ហើយពាក់កណ្ដាលអចិន្ត្រៃយ៍ និងបណ្ដោះអាសន្ននៅឆ្នាំ ២០១៣ មានការថយចុះ បើប្រៀបធៀបឆ្នាំ ២០០៨ ដែលក្នុងនោះអាគារប្រភេទសំណង់បណ្ដោះអាសន្នថយពី ១៩ ភាគរយមកត្រឹម ៧ ភាគរយ នៅឆ្នាំ ២០១៣។

## រូបភាព ២.១០ ការបែងចែកភាគរយអាគារតាមប្រភេទសំណង់




២០០៨ ២០១៣

ប្រភពៈ - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជាពលរដ្ឋកម្ពុជាឆ្នាំ ២០១៣

### ២.២.៣ លំនៅដ្ឋាន

នៅក្នុងប្រទេសកម្ពុជាមានចំនួនគ្រួសារសរុបប្រហែល ៣,៤ លានគ្រួសារ នៅក្នុងឆ្នាំ ២០១៩ ខណៈដែលនៅក្នុងឆ្នាំ ២០១៧ លំនៅដ្ឋានសរុបនៅក្នុងប្រទេសកម្ពុជា ផ្អែកតាមទិន្នន័យមូលដ្ឋានរបស់មន្ទីរផែនការខេត្តមានចំនួន ៣,៣ លានលំនៅដ្ឋាន។ ចំនួនផ្ទះដំបូលប្រក់ស័ង្កសីហ្វីប្រូស៊ីម៉ង់មានចំនួន ១,៧ លានផ្ទះ ស្មើនឹង ៥១,៥ភាគ ច្រើនជាងគេ បន្ទាប់មក ផ្ទះដំបូលប្រក់ក្បឿងមានចំនួន ៩៩៤.៨៥៨ ផ្ទះ ស្មើនឹង ៣០ ភាគរយ ស្ថិតក្នុងលំដាប់លេខរៀងទី ២ ខណៈដែលផ្ទះថ្មមិនមែនបេតុងមានចំនួន ១៧៧.៩៧០ ផ្ទះ ស្មើនឹង ៥,៤ ភាគរយ ស្ថិតក្នុងលំដាប់រៀងទី ៣ ។ លំនៅដ្ឋានប្រភេទផ្ទះថ្មល្វែងមានចំនួន ១៦៤,២៩៧ ស្មើនឹង ៥ ភាគរយ ស្ថិតក្នុងលំដាប់រៀងទី ៤ ខណៈដែលផ្ទះដំបូលប្រក់ស្លឹកស្បូវមានចំនួន ១០៥,៦៤១ផ្ទះ ស្មើនឹង ៣,២ ភាគរយ ស្ថិតលំដាប់ទី ៥ និង លំនៅដ្ឋានប្រភេទភូមិគ្រឹះចំនួន ១៣.៧៦២ ស្មើនឹង ០,៤ភាគរយ ស្ថិតលំដាប់ទី ៦ ជាលំដាប់ចុងក្រោយ ។ តែបើទោះបីជាលំនៅដ្ឋានប្រភេទភូមិគ្រឹះមានចំនួនតិចក៏ដោយ បើប្រៀបធៀបជាមួយលំនៅដ្ឋានប្រភេទផ្សេងៗខាងលើក៏ពិតមែន តែចំនួននេះបានបង្ហាញថា ប្រទេសកម្ពុជាមានប្រភេទលំនៅដ្ឋានទំនើបច្រើន ហើយបន្តកើនឡើងទៀត ដែលបញ្ជាក់អំពីកម្រិតជីវភាពរបស់ប្រជាជនកម្ពុជាមានការកើនឡើងផងដែរ។

**តារាង ២.៣ ចំនួនលំនៅដ្ឋានតាមប្រភេទ ឆ្នាំ ២០១៧**

| ប្រភេទលំនៅដ្ឋាន | ខេត្ត៥ជាប់បឹងទន្លេសាប | តំបន់បឹងទន្លេសាប | កម្ពុជា |
|---|---|---|---|
| ចំនួនផ្ទះដំបូលប្រក់ស្លឹកស្បូវ | 54,176 | 60,100 | 105,641 |
| ចំនួនផ្ទះដំបូលប្រក់ស័ង្កសីហ្វីប្រូស៊ីម៉ង់ | 504,012 | 686,592 | 1,703,217 |
| ចំនួនផ្ទះប្រក់សង្កសីតិចជាង២០សន្លឹក | 46,015 | 61,986 | 146,355 |
| ចំ.ផ្ទះដំបូលប្រក់ក្បឿង | 229,989 | 247,888 | 994,858 |
| ចំ.ផ្ទះថ្មមិនមែនបេតុង | 35,845 | 46,590 | 177,970 |
| ចំ.ផ្ទះថ្មល្វែង | 12,861 | 21,303 | 164,297 |
| ចំ.ផ្ទះភូមិគ្រឹះ(វីឡា) | 1,741 | 2,115 | 13,762 |
| សរុប | **884,639** | **1,126,574** | **3,306,100** |

ប្រភពៈ ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៧

## ២.៣ បរិស្ថាន ទឹកស្អាត និង បង្គន់អនាម័យ

### ២.៣.១ បរិស្ថាន

ផ្អែកលើទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៧ បានបង្ហាញថា ចំនួនគ្រួសារសរុបទូទាំងប្រទេសមានចំនួន ៣.៥០៤.៣៣៣ គ្រួសារ តំបន់បឹងទន្លេសាបមានចំនួន ១,១៧២,៧៨២ គ្រួសារ ស្មើនឹង ៣៦ ភាគរយ ធៀបទៅនឹងចំនួនគ្រួសារសរុបទូទាំងប្រទេស និង ចំនួនគ្រួសារសម្រាប់ខេត្ត ៥ ជាប់បឹងទន្លេសាបមានចំនួន ៩០៩.៩២៨ គ្រួសារ ស្មើនឹង ២៨ ភាគរយធៀបទៅនឹងចំនួនគ្រួសារសរុបទូទាំងប្រទេស តិចជាងចំនួនគ្រួសារនៅតំបន់បឹងទន្លេសាប ៨ ភាគរយ។ ចំនួនគ្រួសារដែលរស់នៅក្នុងតំបន់ការពារឬអភិរក្សទូទាំងប្រទេសមានចំនួន ៤៩.០៨១ គ្រួសារ (១,៤%) តំបន់បឹងទន្លេសាប ៣៥.០៣៧ គ្រួសារ (៣,0%) និង ខេត្ត ៥ ជាប់បឹងទន្លេសាបមានចំនួន ៣១,៥៨៦ គ្រួសារ(៣,៥%) ។ ចំនួនគ្រួសារដែលមានសេវាប្រមូលសំរាមតាមផ្ទះនៅទូទាំងប្រទេសមានចំនួន ៣៤៦.៧៥៥ គ្រួសារ (១0%) តំបន់បឹងទន្លេសាប ៥៣.៨៨0 គ្រួសារ (៤,៦%) និង ខេត្ត ៥ ជាប់បឹងទន្លេសាបមានចំនួន ៣៩,៣៨១ គ្រួសារ (៤,៤%)។ ចំនួនគ្រួសារដែលទទួលរងផលប៉ះពាល់ពីការបំពុលបរិស្ថាននៅទូទាំងប្រទេសមានចំនួន ៤៣.៤៩៤ គ្រួសារ (១,២%) តំបន់បឹងទន្លេសាប ១៧.៥៣៤ គ្រួសារ (១,៥%) និង ខេត្ត ៥ ជាប់បឹងទន្លេសាបមានចំនួន ១១,៨១៤ គ្រួសារ (១,៣%) ។

**តារាង ២.៤ ចំនួនគ្រួសារដែលពាក់ព័ន្ធនឹងបរិស្ថានឆ្នាំ ២០១៧**

| អធិប្បាយ | ខេត្ត ៥ ជាប់បឹងទន្លេសាប | តំបន់បឹងទន្លេសាប | កម្ពុជា |
|---|---:|---:|---:|
| គ្រួសារដែលរស់នៅក្នុងតំបន់ការពារឬអភិរក្ស | 31,586 | 35,037 | 49,081 |
| គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | 39,831 | 53,880 | 346,755 |
| គ្រួសារដែលទទួលរងផលប៉ះពាល់ពីការបំពុលបរិស្ថាន | 11,814 | 17,534 | 43,494 |
| **ចំនួនគ្រួសារសរុប** | **909,928** | **1,172,782** | **3,504,333** |

ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៧

នៅក្នុងរូបភាព ២.១១ បង្ហាញថា គ្រួសារដែលមានសេវាសំរាមតាមផ្ទះមានតែ ៩,៩ ភាគរយ ប៉ុណ្ណោះដែលទទួលបានសេវានេះ ហើយចំនួនគ្រួសារចំនួន ៩0,១ ភាគរយទៀតពុំទាន់បានទទួលសេវាប្រមូលសំរាម ។ នៅក្នុងតំបន់បឹងទន្លេសាប ចំនួនគ្រួសារដែលទទួលបានសេវាប្រមូលសំរាមមានតែ ៤,៦ ភាគរយ តិចជាងទូទាំងប្រទេសជាងពាក់កណ្ដាល និងមានចំនួនច្រើនជាងខេត្ត ៥ ជាប់បឹងទន្លេសាបតិចតួចប្រហែល 0,២ភាគយ ។ ខេត្ត ៥ ជាប់បឹងទន្លេសាប ភាគរយចំនួនគ្រួសារដែលបានទទួលសំរាមមានចំនួន ៤,៤ ភាគរយ ប្រហាក់ប្រហែលនឹងតំបន់បឹងទន្លេសាបដែរ តែតិចជាងទូទាំងប្រទេសជាងពាក់កណ្ដាលស្មើនឹង ៥,៥ ភាគរយ។

រូបភាព ២.១១ ភាគរយគ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះឆ្នាំ ២០១៧




ប្រភព៖ ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៧

## ២.៣.២ ទឹកស្អាត

នៅក្នុងប្រទេសកម្ពុជាភាគរយនៃគ្រួសារ ដែលមានទឹកស្អាតនៅឆ្នាំ ១៩៩៨ មានចំនួន ២៩ ភាគរយ ហើយបានកើនឡើងរហូតដល់ ៧៦ ភាគរយនៅឆ្នាំ ២០១៧ ផ្អែកតាមទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានីខេត្ត ឆ្នាំ ២០១៧ និងផ្អែកតាមប្រភពអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជានៅឆ្នាំ ២០១៧ មានចំនួន ៦៥ ភាគរយ។ នៅក្នុងរវាង១០ឆ្នាំ បើប្រៀបធៀបរវាងឆ្នាំ ១៩៩៨ និង ២០០៨ ភាគរយនៃការប្រើប្រាស់ទឹកស្អាតបានកើនឡើងមានចំនួន ១៨ ភាគរយ ខណៈដែលពីឆ្នាំ ២០០៤ ដល់ ២០០៨ កើនឡើងតែ៣ភាគរយប៉ុណ្ណោះ។ ពីឆ្នាំ២០០៨ ដល់ឆ្នាំ ២០១៣ ភាគរយគ្រួសារមានទឹកស្អាតប្រើប្រាស់បានកើនឡើងមានចំនួន ១០ភាគរយ ហើយបើប្រៀបធៀបរវាងឆ្នាំ ២០០៨ និង ២០១៧ កើនឡើងមានចំនួន ១៩ ភាគរយ។

## រូបភាព ២.១២ ភាគរយគ្រួសារមានទឹកស្អាតប្រើប្រាស់នៅទូទាំងប្រទេស




ប្រភពៈ - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- របាយការណ៍ទូទៅនៃការធ្វើអង្កេតប្រជារាស្ត្រកម្ពុជា អង្កេតចន្លោះជំរឿន ឆ្នាំ ២០០៤
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ ២០១៣
- Cambodia Socio-Economic Survey 2017 ( 2017* )
- ទិន្នន័យមូលដ្ឋាន ( CDB ) មន្ទីរផែនការរាជធានីខេត្ត ឆ្នាំ ២០១៧

រូបភាព ២.១៣ បង្ហាញអំពីគ្រួសារមានទឹកស្អាតប្រើប្រាស់បែងចែកតាមតំបន់នៅ២០១៧ ដែលមានខេត្ត ៥ ជាប់បឹងទន្លេសាប តំបន់បឹងទន្លេសាប និង ទូទាំងប្រទេស ។ តាមទិន្នន័យនេះ ឃើញថា ភាគរយគ្រួសារដែលមានទឹកស្អាតប្រើប្រាស់តិចជាងតំបន់បឹងទន្លេសាបចំនួន ៨,៥ ភាគរយ ខណៈដែលចំនួនភាគរយគ្រួសារ ដែលមានទឹកស្អាតប្រើប្រាស់នៅតំបន់ទន្លេសាបមានចំនួនប្រហាក់ប្រហែលទៅនឹងទូទាំងប្រទេសផងដែរ ។

## រូបភាព ២.១៣ ភាគរយគ្រួសារមានទឹកស្អាតប្រើប្រាស់បែងចែកតាមតំបន់នៅ២០១៧




ប្រភព- ទិន្នន័យមូលដ្ឋាន (CDB) មន្ទីរផែនការរាជធានីខេត្ត ឆ្នាំ ២០១៧

### ២.៣.៣ បង្គន់អនាម័យ

នៅក្នុងឆ្នាំ ១៩៩៨ ភាគរយគ្រួសារមានបង្គន់អនាម័យប្រើប្រាស់មានចំនួន ១២,៨ ភាគរយ ហើយបានកើនឡើងជាលំដាប់ពីឆ្នាំ ២០០៤មានចំនួន ២១,៩ ភាគរយ នៅឆ្នាំ ២០០៨ មានចំនួន ៣៣,៧ ភាគរយ នៅឆ្នាំ ២០១៣ មានចំនួន ៤៨,៨ភាគរយ និងនៅឆ្នាំ ២០១៧ មានចំនួន ៧៣,៥ ភាគរយ។ បើគិតចាប់តាំងពីឆ្នាំ ១៩៩៨ ដល់ ឆ្នាំ ២០១៧ មក ភាគរយគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់បានកើនជិត៦ដង ខណៈដែលពីឆ្នាំ ២០០៨ ដល់ ២០១៧ មានការកើនឡើងជាង២ដង។ ទិន្នន័យនេះ បានបង្ហាញអំពីការយល់ដឹងអំពីអនាម័យរបស់ប្រជាជនរស់នៅជនបទកាន់តែប្រសើរឡើងចាប់តាំងពីឆ្នាំ ១៩៩៨ មក។

## រូបភាព ២.១៤ ភាគរយចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- របាយការណ៍ទូទៅនៃការធ្វើអង្កេតប្រជាសាស្ត្រកម្ពុជា អង្កេតចន្លោះជំរឿន ឆ្នាំ ២០០៤
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជាសាស្ត្រកម្ពុជាឆ្នាំ ២០១៣
- ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៧

នៅក្នុងឆ្នាំ ២០១៧ ភាគរយចំនួនគ្រួសារនៃខេត្ត ៥ ជាប់បឹងទន្លេសាប ដែលមានបង្គន់អនាម័យប្រើប្រាស់មានចំនួន ៦៦ ភាគរយ ប្រហាក់ប្រហែលទៅនឹងភាគរយចំនួនគ្រួសារប្រជាជនដែលមានបង្គន់អនាម័យប្រើប្រាស់នៅតំបន់បឹងទន្លេសាបដែរ ប៉ុន្តែមានភាគរយទាបជាងទូទាំងប្រទេសដែលមាន ៧៣,៥ ភាគរយ ។ ទិន្នន័យនេះ បង្ហាញថា ប្រជាជនទាំងនៅខេត្ត ៥ ជាប់បឹងទន្លេសាប និង ប្រជាជនដែលរស់នៅតំបន់បឹងទន្លេសាបទាំងមូលពុំទាន់យល់ដឹងពីអនាម័យនៅឡើយ ដែលធ្វើឲ្យមានផលប៉ះពាល់បរិស្ថាន និងសុខភាពរបស់ពួកគាត់ផ្ទាល់ផងដែរ។

**រូបភាព ២.១៥ ភាគរយចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់បែងចែកតាមតំបន់ ឆ្នាំ ២០១៧**




ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៧

## ២.៤ គ្រោះមហន្តរាយ

គ្រោះមហន្តរាយធម្មជាតិដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា គឺគ្រោះទឹកជំនន់ ខ្យល់ព្យុះ និងគ្រោះរាំងស្ងួត មិនមែនគ្រោះរលកស៊ូណាមិ និង គ្រោះរញ្ជួយដីដូចប្រទេសផ្សេងទេ ។ ចំនួនគ្រោះមហន្តរាយដោយគ្រោះទឹកជំនន់មានចំនួន ៦៥ភាគរយ គ្រោះរាំងស្ងួតមានចំនួន ២២ ភាគរយ និង ខ្យល់ព្យុះ ១៣ភាគរយ ចាប់ពីឆ្នាំ ១៩៨០ ដល់ ២០១១ ផ្អែកតាមរបាយការណ៍របស់អង្គការ JICA ឆ្នាំ ២០១៥ ស្តីពីការវាយតម្លៃគ្រោះមហន្តរាយធម្មជាតិ និង ការរៀបចំផែនការបន្តអាជីវកម្មសម្រាប់តំបន់ឧស្សាហកម្មនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ គ្រោះមហន្តរាយ គឺបានធ្វើឲ្យបាត់បង់ជីវិតមនុស្ស សត្វ ខូចខាតសម្ភារៈប្រើប្រាស់ផ្សេងៗ និងប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចយ៉ាងខ្លាំង ជាពិសេសការខូចខាតផលដំណាំកសិកម្ម និងវិស័យដទៃទៀត ។

ក្នុងចំណោមប្រភេទគ្រោះមហន្តរាយធម្មជាតិ ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជានោះ គឺគ្រោះមហន្តរាយខ្យល់ព្យុះ ទឹកជំនន់ និងគ្រោះរាំងស្ងួត បានធ្វើឲ្យប៉ះពាល់ដល់ការរស់នៅរបស់ប្រជាជនក្នុងការប្រកបរបររកស៊ីប្រចាំថ្ងៃ ។ គ្រោះរាំងស្ងួតបានកើតឡើងគឺធ្វើឲ្យប៉ះពាល់ដល់ចំនួនគ្រួសារ មានចំនួនច្រើនជាងគេរហូតដល់ ៥៧.៨១៦ គ្រួសារ សម្រាប់ទូទាំងប្រទេស តំបន់បឹងទន្លេសាបមានចំនួន ៤១.១៧៥ គ្រួសារ និង ខេត្ត ៥ ជាប់បឹងទន្លេសាបមានចំនួន ២៧.៦២០ គ្រួសារ។ គ្រោះទឹកជំនន់ជាប្រភេទគ្រោះមហន្តរាយលំដាប់លេខ ២ បន្ទាប់ពីគ្រោះរាំងស្ងួតដែលធ្វើឲ្យប៉ះពាល់ដល់ចំនួនគ្រួសារ ១៧.២១៣ គ្រួសារ សម្រាប់ទូទាំងប្រទេស តំបន់បឹងទន្លេសាបមានចំនួន ៣.៩៣៤ គ្រួសារ និង ខេត្ត ៥ ជាប់បឹងទន្លេសាបមានចំនួន ២.៨៨៩ គ្រួសារ ។ គ្រោះមហន្តរាយខ្យល់ព្យុះស្ថិតនៅក្នុងលំដាប់ទី ៣ គឺលំដាប់ចុងក្រោយបន្ទាប់ពីគ្រោះទឹកជំនន់ ដែលប៉ះពាល់ដល់គ្រួសារចំនួន ២.៥៨៤ គ្រួសារ សម្រាប់ទូទាំងប្រទេស តំបន់បឹងទន្លេសាប ១.៤៣០ គ្រួសារ និង ខេត្ត ៥ ជាប់បឹងទន្លេសាប ៩៣៨ គ្រួសារ។

**រូបភាព ២.១៦ ចំនួនគ្រួសារដែលរងគ្រោះដោយគ្រោះមហន្តរាយបែងចែកតាមតំបន់ ឆ្នាំ ២០១៧**




ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៧

គ្រោះមហន្តរាយបានបណ្តាលឲ្យមនុស្សស្លាប់នៅទូទាំងប្រទេសឆ្នាំ ២០១៧ មានចំនួន ៤៤៣ នាក់ ដែលក្នុងនោះគ្រោះទឹកជំនន់បានបណ្តាលឲ្យមនុស្សស្លាប់រហូតដល់ ២៦៤នាក់ រន្ទះបាញ់ ១៣៧ នាក់ និង ខ្យល់ព្យុះមានចំនួនអ្នកស្លាប់ ៤២ នាក់ ។ នៅក្នុងតំបន់បឹងទន្លេសាបចំនួនមនុស្សស្លាប់សរុប ២០៥ នាក់ ដែលក្នុងនោះគ្រោះទឹកជំនន់បានបណ្តាលឲ្យមនុស្សស្លាប់ចំនួន ១២៧ នាក់ ស្លាប់ដោយរន្ទះបាញ់ ៧១ នាក់ និង ស្លាប់ដោយខ្យល់ព្យុះមានចំនួន ៧ នាក់ និង ខេត្ត ៥ ជាប់បឹងទន្លេសាបមានចំនួនអ្នកស្លាប់ដោយគ្រោះទឹកជំនន់មានរហូតដល់ ៨៩នាក់ រន្ទះបាញ់ ៥៤នាក់ និង ខ្យល់ព្យុះមានចំនួនអ្នកស្លាប់ ៣ នាក់ ។

**រូបភាព ២.១៧ ចំនួនអ្នកស្លាប់ដោយសារគ្រោះមហន្តរាយ ឆ្នាំ ២០១៧**




ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៧

## ២.៥ ការប្រែប្រួលអាកាសធាតុ

ប្រទេសកម្ពុជាមានផ្ទៃដី ១៨១.០៣៥ គីឡូម៉ែត្រក្រឡា ស្ថិតនៅភាគនិរតីនៃឧបទ្វីបអាស៊ីបូព៌ា ហើយផ្ទៃដីប្រមាណ ២០ ភាគរយត្រូវបានប្រើប្រាស់សម្រាប់ដំណាំកសិកម្ម ។ ប្រទេសកម្ពុជាស្ថិតនៅក្នុងតំបន់ត្រូពិកទាំងស្រុង និងស្ថិតនៅចំណុចខាងត្បូងច្រើនជាង ១០ អង្សានៅលើអេក្វាទ័រ។ សីតុណ្ហភាពអតិបរមាខ្ពស់ជាង ៣៣ អង្សាសេ ជាទូទៅចាប់ផ្តើមរដូវវស្សានៅខែមីនា និងខែមេសា ហើយអាចកើនឡើងដល់ ៣៨ អង្សាសេ។ សីតុណ្ហភាពអប្បបរមាធ្លាក់នៅក្រោម ១០ អង្សាសេ ។ នៅ ខែមករាជាខែត្រជាក់បំផុត និង ខែមេសាជាខែដែលក្តៅបំផុត។ បរិមាណទឹកភ្លៀងប្រចាំឆ្នាំគឺរវាង ១៤២ និង ២០០ សង់ទីម៉ែត្រ ។ ភ្លៀងធ្លាក់ពីខែ មេសាដល់ខែកញ្ញាក្នុងតំបន់ដីទំនាបបឹងទន្លេសាប មេគង្គ ជា

មធ្យមប្រចាំឆ្នាំពី ១១០ ទៅ ១៩០ សង់ទីម៉ែត្រ ប៉ុន្តែបរិមាណនេះប្រែប្រួលដែលគួរឲ្យកត់សំគាល់ពីមួយឆ្នាំទៅមួយឆ្នាំ ។ តែទោះបីយ៉ាងណាក៏ដោយ តំបន់ទឹកភ្លៀងដ៏ធំបំផុតនេះភាគច្រើនហូរទៅសមុទ្រ ហើយមានបរិមាណតិចតួចប៉ុណ្ណោះ ដែលហូរតាមស្ទឹងទន្លេចូលក្នុងបឹងទន្លេសាប។ សំណើមនៅប្រទេសកម្ពុជា គឺខ្ពស់នៅពេលយប់ពេញមួយឆ្នាំ និងនៅពេលរដូវប្រាំងសំណើមមធ្យមប្រមាណ ៥០ ភាគរយ ឬ ទាបជាងបន្តិច ប៉ុន្តែវាអាចមានប្រមាណ ៦០ ភាគរយ នៅរដូវវស្សា។

## ២.៥.១ ស្ថានភាពទឹកភ្លៀង

កម្ពស់ទឹកភ្លៀងជាមធ្យមនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ ២០១០ ដល់ ២០១៥ មានធ្លាក់ចុះមក ពី ១.៥៨៣,៦ មីលីម៉ែត្រនៅឆ្នាំ ២០២១០ មកត្រឹម ១.៤០៧,៦ មីលីម៉ែត្រនៅឆ្នាំ ២០១៥ ខណៈដែនៅឆ្នាំ ២០១១ និងឆ្នាំ ២០១៣ មានលក្ខណៈប្រហាក់ប្រហែលគ្នាពីចន្លោះ ១,៧៦៧មីលីម៉ែត្រទៅ ១,៧៨១ មីលីម៉ែត្រ និងនៅក្នុងឆ្នាំ ២០១២ និងឆ្នាំ ២០១៤ មានលក្ខណៈប្រហាក់ប្រហែលគ្នាពីចន្លោះ ១.៦៣២ មីលីម៉ែត្រទៅ១.៦៦០ មីលីម៉ែត្រ។ ចំពោះតំបន់បឹងទន្លេសាប និងខេត្ត ៥ ជាប់បឹងទន្លេសាបមាននិន្នាការទាបជាងទូទាំងប្រទេសប៉ុន្តែខ្ពស់ជាងទូទាំងប្រទេសនៅឆ្នាំ ២០១៤ និង ធ្លាក់ចុះយ៉ាងគំហុកទាបជាងទូទាំងប្រទេសនៅក្នុងឆ្នាំ ២០១៥ មកត្រឹមប្រហាក់ប្រហែល ១.១២០ មីលីម៉ែត្រ។

**រូបភាព ២.១៨ កម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ តាមស្ថានីយ៍គិតជាមីលីម៉ែត្រ**




ប្រភព: នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

និន្នាការនៃចំនួនថ្ងៃមានភ្លៀងធ្លាក់ជាមធ្យម បើពិនិត្យជារួមសម្រាប់នៅទូទាំងប្រទេសមានការថយចុះ ហើយនិន្នាការនៃចំនួនថ្ងៃមានភ្លៀងធ្លាក់នៅក្នុងខេត្តបាត់ដំបង និងសៀមរាបមានស្ថានភាពដូចនៅទូទាំងប្រទេសដែរ ប៉ុន្តែខេត្តបន្ទាយមានជ័យមាននិន្នាការកើនឡើងខុសពីស្ថានភាពនៅទូទាំងប្រទេស និងខេត្តទាំងពីរខាងលើ។ និន្នាការចំនួនថ្ងៃមានភ្លៀងធ្លាក់ជាមធ្យមនៅទូទាំងប្រទេសមានការកើនឡើងនៅក្នុងឆ្នាំ ២០១១ និង ២០១២ ហើយបន្តធ្លាក់ចុះរហូតដល់ឆ្នាំ ២០១៥ ខណៈដែលខេត្តបាត់ដំបងបានកើនឡើងបន្តិចនៅឆ្នាំ ២០១៣ ហើយបានធ្លាក់ចុះនៅឆ្នាំ ២០១៤ និងនៅឆ្នាំ ២០១៥ រក្សាស្ថានភាពដដែល និងខេត្តសៀមរាបបានថយចុះនៅឆ្នាំ ២០១៣ ហើយបានកើនឡើងនៅឆ្នាំ ២០១៤ និងបានធ្លាក់ចុះនៅឆ្នាំ ២០១៥។ ចំណែកឯខេត្តបន្ទាយមានជ័យបានកើនឡើងខ្ពស់នៅឆ្នាំ ២០១១ និង ២០១២ និងបានធ្លាក់ចុះបន្តិចនៅឆ្នាំ ២០១៣ ហើយបានកើនឡើងចាប់ពីឆ្នាំ ២០១៤។

**រូបភាព ២.១៩ ចំនួនថ្ងៃមានភ្លៀងក្នុងឆ្នាំគិតជាមធ្យមតាមស្ថានីយ៍**




ប្រភព: នាយកដ្ឋានឧតុនិយម ក្រសួងធនធានទឹក និង ឧតុនិយម

## ២.៥.២ សីតុណ្ហភាព

តារាង ២.៥ បង្ហាញអំពី សីតុណ្ហភាពអប្បបរមានិងអតិបរិមាគិតជាអង្សាសេតាមខេត្តមួយចំនួន ដែលមានស្ថានីយ៍វាស់ស្ទង់សីតុណ្ហភាព។ តាមទិន្នន័យក្នុងតារាង ឃើញថាសីតុណ្ហភាពអប្បបរមាគិតជាមធ្យមរយៈពេល ៥ ឆ្នាំ មានចំនួន២១,៥ អង្សាសេខ្ពស់ជាងខេត្តប៉ៃលិនដែលមានចំនួន ១៩,៣ អង្សាសេ និងទាបជាងខេត្តបាត់ដំបងមានចំនួន ២២,៨ អង្សាសេ ហើយខេត្តផ្សេងទៀតមានចំនួនប្រហាក់ប្រហែលទូទាំងប្រទេសដែរ ។ នៅក្នុងតារាងនេះផងដែរ ឃើញថា សីតុណ្ហភាពអតិប្បរមាគិតជាមធ្យមរយៈពេល ៥ ឆ្នាំ មានចំនួន ៣៤,៩ អង្សាសេ ប្រហាក់ប្រហែលខេត្តសៀមរាប តែខ្ពស់ជាងខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ធំ និងទាបជាងខេត្តបាត់ដំបង ពោធិ៍សាត់ និង ខេត្តប៉ៃលិន ។

**តារាង ២.៥ សីតុណ្ហភាព អប្បបរមានិងអតិបរិមា តាមស្ថានីយ៍ គិតជាអង្សាសេ**

| ខេត្ត | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | គិតមធ្យម រយៈពេល៥ឆ្នាំ |
|---|---|---|---|---|---|---|
| **អប្បបរមា** | | | | | | |
| បន្ទាយមានជ័យ | 19.7 | 20.7 | 24.1 | 20.0 | 21.8 | 21.3 |
| បាត់ដំបង | 21.3 | 22.0 | 22.0 | 26.6 | 22.1 | 22.8 |
| កំពង់ធំ | 20.4 | 22.8 | 22.5 | 21.7 | 22.1 | 21.9 |
| ពោធិ៍សាត់ | 20.7 | 21.6 | 21.1 | 21.7 | 21.9 | 21.4 |
| សៀមរាប | 20.4 | 22.7 | 22.1 | 21.9 | 22.0 | 21.8 |
| ប៉ៃលិន | 20.7 | 20.5 | 18.1 | 18.8 | 18.8 | 19.3 |
| **ទូទាំងប្រទេស** | **20.8** | **20.9** | **21.8** | **21.9** | **22.1** | **21.5** |
| **អតិបរមា** | | | | | | |
| បន្ទាយមានជ័យ | 36.2 | 34.4 | 24.1 | 34.6 | 36.2 | 33.1 |
| បាត់ដំបង | 34.5 | 36.1 | 36.2 | 36.3 | 36.2 | 35.8 |
| កំពង់ធំ | 31.7 | 34.6 | 33.2 | 33.3 | 35.8 | 33.7 |
| ពោធិ៍សាត់ | 35.3 | 36.1 | 36.2 | 36.2 | 37 | 36.2 |
| សៀមរាប | 34.7 | 33.4 | 36.3 | 35.7 | 36.1 | 35.2 |
| ប៉ៃលិន | 34.5 | 35.4 | 35 | 36.75 | 36.7 | 35.8 |
| **ទូទាំងប្រទេស** | **34.5** | **35.1** | **34.2** | **35.0** | **35.9** | **34.9** |

ប្រភព: នាយកដ្ឋានឧតុនិយម ក្រសួងធនធានទឹក និង ឧតុនិយម

រូបភាព ២.២០ បង្ហាញអំពីនិន្នាការនៃសីតុណ្ហភាពអតិបរិមា និងអប្បបរមា នៅទូទាំងប្រទេស តាមស្ថានីយ៍គិតជាអង្សាសេ ។ ពិនិត្យជារួមនិន្នាការសីតុណ្ហភាពពីឆ្នាំ ២០១១ ដល់ ២០១៥ មានការប្រែប្រួលតិចតួច តែអ្វីគួរកត់សំគាល់សីតុណ្ហភាពបានកើនឡើងចាប់ពីឆ្នាំ ២០១៣ ឡើងទៅ។

**រូបភាព ២.២០ សីតុណ្ហភាពអតិបរិមា និងអប្បបរមា ទូទាំងប្រទេស តាមស្ថានីយ៍ គិតជាអង្សាសេ**




ប្រភព: នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

## ២.៥.៣ កម្ពស់ទឹក

នៅក្នុងរូបភាព ២.២១ បង្ហាញអំពីស្ថានភាពទូទៅនៃកម្ពស់ទឹកទន្លេមេគង្គគិតជាម៉ែត្រពីឆ្នាំ ១៩៩០ ដល់ ២០១៥ តាមស្ថានីយដែលរួមមាន ស្ទឹងត្រែង ក្រចេះ កំពង់ចាម និង បាសាក់ ។ និន្នាការជារួម គឺកំពស់ទឹកមានការប្រែប្រួលបើគិតពីឆ្នាំ ១៩៩០ មកទល់ឆ្នាំ ២០១៥ មក។ កម្ពស់ទឹកនៅក្នុងឆ្នាំ ២០១៥ មានកម្ពស់ទឹកទាបជាង ៣ ម៉ែត្រគិតជាមធ្យម បើប្រៀបធៀបនឹងឆ្នាំ១៩៩០ និងទាបជាងឆ្នាំ ២០១៤ ប្រហែល ៣,៥ ម៉ែត្រ គិតជាមធ្យម ប៉ុន្តែវាមានចំនួនប្រហាក់ប្រហែលនឹងឆ្នាំ ១៩៩៨ និងឆ្នាំ២០១២។

## រូបភាព ២.២១ កំពស់ទឹកទន្លេមេគង្គ គិតជាម៉ែត្រ




ប្រភព: នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

# ជំពូក ៣
# ការវិភាគលទ្ធផល

## ៣.១ ព័ត៌មានទូទៅ

### ៣.១.១ គ្រួសារ

នៅក្នុងការចុះសម្ភាសន៍ស្រង់ទិន្នន័យជាក់ស្តែងនៅក្នុងខេត្តទាំង ៥ សម្រាប់តំបន់ដែលជាប់បឹងទន្លេសាប តារាងបញ្ជីសំណួរ ២ ត្រូវបានប្រើប្រាស់មានតារាងបញ្ជីសំណួរសម្រាប់សួរទៅមេភូមិនូវព័ត៌មាននៅក្នុងភូមិទាំងមូល និងតារាងបញ្ជីសំណួរសម្រាប់សួរមេគ្រួសារ គឺសម្ភាសន៍មេគ្រួសារផ្ទាល់។

តារាង ៣.១ បង្ហាញអំពីចំនួនគ្រួសារប្រជាជនទាំង ១៥ ភូមិ នៅក្នុងខេត្តគោលដៅទាំង ៥ ដែលបានសម្ភាសន៍មេភូមិទាំង ១៥ នាក់។ ចំនួនគ្រួសារប្រជាជនពិនិត្យជារួមក្នុងខេត្តទាំង ៥ មានការកើនឡើងចំនួន ២៧៩គ្រួសារ ពីឆ្នាំ ២០១៦ ដល់ ២០១៨ ប៉ុន្តែបើពិនិត្យខេត្តកំពង់ឆ្នាំង និងសៀមរាប មានការថយចុះ ។តែទោះបីយ៉ាងណាក៏ដោយ ចំនួនគ្រួសារប្រជាជនមានការកើនឡើងជាបន្តបន្ទាប់។

**តារាង ៣.១ ចំនួនគ្រួសារសរុបភូមិគោលដៅតាមបណ្តាខេត្តចុះសម្ភាសន៍**

| លេខរៀង | ខេត្ត | ចំនួនគ្រួសារ | | |
|---|---|---|---|---|
| | | ២០១៦ | ២០១៧ | ២០១៨ |
| ១ | កំពង់ឆ្នាំង | 897 | 918 | 791 |
| ២ | ពោធិ៍សាត់ | 802 | 837 | 899 |
| ៣ | បាត់ដំបង | 1,229 | 1,266 | 1,331 |
| ៤ | សៀមរាប | 568 | 611 | 777 |
| ៥ | កំពង់ធំ | 991 | 1,017 | 968 |
| សរុប | | **4,487** | **4,649** | **4,766** |

តារាង ៣.២ បង្ហាញតួលេខចំនួនគ្រួសារបែងចែកតាមក្រុមអាយុក្នុងចំណោមមេគ្រួសារទាំង ១.៥០០ នាក់ ដែលបានចុះសម្ភាសន៍ផ្ទាល់នៅក្នុងភូមិគោលដៅ ។ តាមតួលេខ ចំនួនតួលេខមេគ្រួសារក្រុមអាយុពី៤០ ដល់ ៦៩ ឆ្នាំ មានចំនួន ៨៨៥ នាក់ (៥៩%) មេគ្រួសារស្ថិតក្នុងក្រុមអាយុ ១៥ ដល់ ៣៩ ឆ្នាំ មានចំនួន ៥០៩ នាក់ (៣៤%) និង មេគ្រួសារស្ថិតក្នុងក្រុមអាយុ ៧០ឆ្នាំ ឡើងមានចំនួន ១០៦នាក់ (៧%) បើប្រៀបធៀបទៅនឹងចំនួនមេគ្រួសារសរុប។ មេគ្រួសារភាគច្រើនជាបុរសមានចំនួន ១.០៤០ នាក់ (៦៣,៩%) និង មេគ្រួសារមានចំនួន ៤៦០ នាក់ (៣០,៧%)។

**តារាង ៣.២ ចំនួនមេគ្រួសារ បែងចែកតាមក្រុមអាយុ**

| ក្រុមអាយុ | ភេទមេគ្រួសារ | | |
|---|---|---|---|
| | ប្រុស | ស្រី | ទាំងពីរភេទ |
| ១៥ ដល់ ៣៩ឆ្នាំ | 377 | 132 | 509 |
| ៤០ ដល់ ៦៩ឆ្នាំ | 593 | 292 | 885 |
| ៧០ឆ្នាំ ឡើង | 70 | 36 | 106 |
| **សរុប** | **1,040** | **460** | **1,500** |

## ៣.១.២ ទំហំគ្រួសារ

រូបភាព ៣.១ បង្ហាញអំពីចំនួនសមាជិកគ្រួសារគិតជាមធ្យម និងប្រៀបធៀបជាមួយនឹងប្រភពផ្សេងៗទៀត។ ចំនួនសមាជិកជាមធ្យមគិតពីឆ្នាំ ១៩៩៨ មកដល់ឆ្នាំ ២០១៧ មានចំនួនធ្លាក់ចុះពី ៥,២ នាក់ មក ៤,៥ នាក់ក្នុងមួយគ្រួសារ និង នៅឆ្នាំ ២០១៩ មានសមាជិកជាមធ្យមចំនួន ៤,៦ នាក់ក្នុងមួយគ្រួសារ។ ចំនួនសមាជិកពីឆ្នាំ ២០០៨ ដល់ ឆ្នាំ ២០១៩ មានការថយចុះតិចតួចលើកលែងតែឆ្នាំ ២០១៣ និងឆ្នាំ ២០១៩ មានចំនួនស្មើគ្នា ប៉ុន្តែលទ្ធផលដែលទទួលបានការចុះស្រង់ទិន្នន័យតាមភូមិគោលដៅក្នុងខេត្ត ៥ ជាប់បឹងទន្លេសាប គឺទំហំគ្រួសារគិតជាមធ្យមមានសមាជិក ៥ នាក់ក្នុងមួយគ្រួសារ ធំជាងឆ្នាំ ២០១៩ និង ឆ្នាំ ២០១៧ ។ចំនួននេះអាចបណ្តាលមកពីគ្រួសារដែលបានចុះសម្ភាសន៍ស្រង់ទិន្នន័យជាគ្រួសារនៅតំបន់ជនបទ ។

**រូបភាព ៣.១ ទំហំគ្រួសារគិតជាមធ្យម**



## ៣.១.៣ ចំណាកស្រុក

ទិន្នន័យនៅក្នុង តារាង ៣.៣ បង្ហាញថា ចំនួនប្រជាជន ១.០៥៣ នាក់ ស្មើនឹង ១៤,២ភាគរយ នៅក្នុងចំណោមប្រជាជន ៧.៤២៥ នាក់ បានធ្វើចំណាកស្រុកទាំងក្នុង និងក្រៅប្រទេស ដែលនៅក្នុងនោះចំនួនប្រជាជន ៧៨៥នាក់ (១០,៦%) បានធ្វើចំណាកស្រុកក្នុងប្រទេស និង ចំនួនប្រជាជន ២៦៨ នាក់ (៣,៦%) បានធ្វើចំណាកស្រុកទៅក្រៅប្រទេស។ នៅក្នុងចំនួនប្រជាជនដែលបានធ្វើចំណាកស្រុក គឺចំនួនសមាជិកភេទប្រុស ដែលបានធ្វើចំណាកស្រុកមានចំនួន ៥៦២នាក់ (៥៣,៤%) និង ភេទស្រីមាន ៤៩១នាក់ (៤៦,៦%) ។ ទិន្នន័យនេះក៏បានបង្ហាញផងដែរថាចំណាកស្រុកក្នុងប្រទេសសម្រាប់ប្រជាជនទាំងពីរភេទមានចំនួនច្រើនជាងចំណាកស្រុកទៅក្រៅប្រទេស។

**តារាង ៣.៣ ចំនួនសមាជិកអចិន្ត្រៃយ៍ និង សមាជិកចំណាកស្រុក**

| អធិប្បាយ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| **សមាជិកអចិន្ត្រៃយ៍** | 3,587 | 3,838 | 7,425 |
| **សមាជិកចំណាកស្រុក** | 562 | 491 | 1,053 |
| សមាជិកចំណាកស្រុកក្នុងប្រទេស | 391 | 394 | 785 |
| សមាជិកចំណាកស្រុកក្រៅប្រទេស | 171 | 97 | 268 |

រូបភាព ៣.២ បង្ហាញថា ភាគរយសមាជិកគ្រួសារដែលបានធ្វើចំណាកស្រុកក្នុងប្រទេសមានចំនួន ៧៤,៥ ភាគរយ ខណៈដែលការធ្វើចំណាកស្រុកទៅក្រៅប្រទេសមានតែ ២៥,៥ ភាគរយ ។ ភាគរយសមាជិកគ្រួសារភេទស្រី គឺបានធ្វើចំណាកស្រុកនៅក្នុងប្រទេសច្រើនជាងសមាជិកគ្រួសារភេទប្រុស ហើយផ្ទុយទៅវិញចំពោះសមាជិកគ្រួសារភេទប្រុសបានធ្វើចំណាកស្រុកក្រៅប្រទេសច្រើនជាងសមាជិកគ្រួសារភេទស្រី។

**រូបភាព ៣.២ ភាគរយសមាជិកគ្រួសារធ្វើចំណាកស្រុក**



## ក.ចំណាកស្រុកក្នុងប្រទេស

ទិន្នន័យក្នុងរូបភាព ៣.៣ បានបង្ហាញថា រាជធានីខេត្តដែលមានសមាជិកគ្រួសារបានធ្វើចំណាកស្រុកពីខេត្តផ្សេងចូលទៅក្នុង ២៥ រាជធានីខេត្តក្នុងព្រះរាជាចក្រកម្ពុជា គឺភាគរយដែលខ្ពស់ជាងគេ រាជធានីភ្នំពេញ ខេត្តសៀមរាប ព្រះសីហនុ បន្ទាយមានជ័យ បាត់ដំបង កំពង់ធំ ជាដើម ខណៈដែលខេត្តកែប និងព្រៃវែង ពុំមានចំណាកស្រុកចូលក្នុងខេត្តទាំងពីរនេះ ។

**រូបភាព ៣.៣ ភាគរយចំនួនសមាជិកគ្រួសារបានធ្វើចំណាកស្រុកតាមបណ្ដាខេត្ត**




តារាង ៣.៤ បានបង្ហាញពីសមាជិកគ្រួសារបានធ្វើចំណាកស្រុកទៅតាមរាជធានីខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។ ទិន្នន័យនេះបង្ហាញថា សមាជិកចំណាកស្រុកភេទស្រីបានធ្វើចំណាកស្រុកចូលរាជធានីខេត្ត មានចំនួនច្រើនជាងរួមមាន កំពង់ឆ្នាំង កណ្ដាល រាជធានីភ្នំពេញ ពោធិ៍សាត់ សៀមរាប ស្វាយរៀង និង ខេត្តត្បូងឃ្មុំ ហើយក្រៅពីខេត្តទាំងអស់នេះគឺសមាជិកចំណាកស្រុកភេទប្រុសចូលទៅខេត្តដែលមិនបានរៀបរាប់ខាងលើ មានចំនួនច្រើនសមាជិកចំណាកស្រុកភេទស្រីរួមមាន ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ធំ កំពត កោះកុង ក្រចេះ មណ្ឌលគិរី ព្រះវិហារ ព្រះសីហនុ តាកែវ និងខេត្តឧត្តរមានជ័យ ។

តារាង ៣.៤ ចំនួនសមាជិកចំណាកស្រុកចូលទៅតាមរាជធានីខេត្ត

| ឈ្មោះខេត្ត | ប្រុស | ស្រី | សរុប |
|---|---|---|---|
| បន្ទាយមានជ័យ | 19 | 16 | 35 |
| បាត់ដំបង | 16 | 8 | 24 |
| កំពង់ចាម | 2 | 0 | 2 |
| កំពង់ឆ្នាំង | 4 | 8 | 12 |
| កំពង់ស្ពឺ | 1 | 1 | 2 |
| កំពង់ធំ | 13 | 8 | 21 |
| កំពត | 3 | 0 | 3 |
| កណ្តាល | 0 | 2 | 2 |
| កោះកុង | 2 | 1 | 3 |
| ក្រចេះ | 2 | 1 | 3 |
| មណ្ឌលគីរី | 4 | 0 | 4 |
| រាជធានីភ្នំពេញ | 234 | 269 | 503 |
| ព្រះវិហារ | 3 | 0 | 3 |
| ព្រៃវែង | 0 | 0 | 0 |
| ពោធិ៍សាត់ | 1 | 8 | 9 |
| រតនគីរី | 2 | 0 | 2 |
| សៀមរាប | 45 | 56 | 101 |
| ព្រះសីហនុ | 34 | 8 | 42 |
| ស្ទឹងត្រែង | 0 | 0 | 0 |
| ស្វាយរៀង | 1 | 4 | 5 |
| តាកែវ | 2 | 0 | 2 |
| ឧត្តរមានជ័យ | 2 | 0 | 2 |
| កែប | 0 | 0 | 0 |
| ប៉ៃលិន | 1 | 1 | 2 |
| ត្បូងឃ្មុំ | 0 | 3 | 3 |
| **សរុប** | **391** | **394** | **785** |

## ក១.មូលហេតុនៃចំណាកស្រុកក្នុងប្រទេស

តារាង ៣.៥ បង្ហាញអំពីមូលហេតុដែលសមាជិកនៅក្នុងគ្រួសារបានធ្វើចំណាកស្រុកទៅតាមរាជធានីខេត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទិន្នន័យនេះ បានបង្ហាញថា ចំនួនសមាជិកបានធ្វើចំណាកស្រុក ដោយសារតែការស្វែងរកការងារធ្វើមានចំនួនច្រើនជាងគេមានចំនួន ៥៨៤នាក់ (៧៤,៤%) មូលហេតុផ្សេងៗមានចំនួន១៤០នាក់ (១៧,៨%) មូលហេតុការសិក្សាមានចំនួន ៥១ នាក់ (៦,៥%) មូលហេតុគ្រួសារផ្លាស់លំនៅដ្ឋានមានចំនួន៥នាក់ (០,៦%) និង មូលហេតុនៃការប្តូរទីកន្លែងការងារមានចំនួន ៥នាក់ (០,៦%) នៅក្នុងចំណោមសមាជិកចំណាកស្រុកសរុប។

តារាង ៣.៥ **មូលហេតុចំណាកស្រុកនៅក្នុងប្រទេស**

| មូលហេតុចំណាកស្រុកនៅក្នុងប្រទេស | សរុប | ប្រុស | ស្រី |
|---|---|---|---|
| ប្តូរកន្លែងការងារ | 5 | 2 | 3 |
| ស្វែងរកការងារធ្វើ | 584 | 293 | 291 |
| ការសិក្សា | 51 | 26 | 25 |
| គ្រួសារផ្លាស់ប្តូរលំនៅដ្ឋាន | 5 | 3 | 2 |
| មូលហេតុផ្សេងៗ | 140 | 67 | 73 |
| **សរុប** | **785** | **391** | **394** |

### រូបភាព ៣.៤ ភាគរយសមាជិកចំណាកស្រុកតាមមូលហេតុ



## ខ.ចំណាកស្រុកក្រៅប្រទេស

តារាង ៣.៦ បង្ហាញថា ចំនួនសមាជិកដែលបានធ្វើចំណាកស្រុកទៅប្រទេសថៃមានចំនួន ២១៦ នាក់ (៨០%) ក្នុងចំណោមចំនួនសមាជិកចំណាកស្រុកសរុប ២៦៨ នាក់ ហើយបន្ទាប់មកប្រទេសកូរ៉េខាងត្បូង មានចំនួន ៣៤នាក់ (១២,៧%) ម៉ាឡេស៊ី ៦នាក់ (២,២%) ញ៉ូវែសាឡែន ៥នាក់ (១,៩%) ខណៈដែលសមាជិកបានធ្វើចំណាកស្រុកទៅប្រទេសជប៉ុន និងចិនមានចំនួនដូចគ្នា ៣នាក់ (១,១%) និង ប្រទេសឡាវមានតែ ១នាក់ (០,៤%)។

**តារាង ៣.៦ ចំនួនសមាជិកចំណាកស្រុកតាមប្រទេស**

| ឈ្មោះប្រទេស | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|
| ថៃ | 216 | 145 | 71 |
| ឡាវ | 1 | 1 | 0 |
| ម៉ាឡេស៊ី | 6 | 1 | 5 |
| កូរ៉េខាងត្បូង | 34 | 18 | 16 |
| ចិន | 3 | 0 | 3 |
| ជប៉ុន | 3 | 1 | 2 |
| ញ៉ូវែសាឡែន | 5 | 5 | 0 |
| **សរុប** | **268** | **171** | **97** |

**រូបភាព ៣.៥ ភាគរយសមាជិកចំណាកស្រុកទៅក្រៅប្រទេស**



## ១១.មូលហេតុនៃចំណាកស្រុកទៅក្រៅប្រទេស

តារាង ៣.៧ បង្ហាញថាចំនួនសមាជិកបានធ្វើចំណាកស្រុកដោយសារតែស្វែងរកការងារធ្វើមានចំនួន ២៤៨ នាក់ (៩២,៥%) ក្នុងចំណោមចំនួនសមាជិកដែលបានធ្វើចំណាកស្រុកសរុប ។ ចំពោះសមាជិកដែលបានធ្វើចំណាកស្រុកទៅក្រៅប្រទេស ដោយសារមូលហេតុផ្សេងៗមានចំនួន ១៦ នាក់ (៦%) ខណៈដែលអ្នកចំណាកស្រុកទៅក្រៅប្រទេសដោយសារការប្តូរកន្លែងការងារ ការសិក្សា និងទៅលេងសាច់ញ្ញាតិមានចំនួនតិចតួច។ ជារួមសមាជិកចំណាកស្រុកភេទប្រុសមានចំនួនច្រើនជាងភេទស្រី ។

### តារាង ៣.៧ ចំនួនសមាជិកចំណាកស្រុកទៅក្រៅប្រទេសតាមមូលហេតុ

| មូលហេតុចំណាកស្រុកទៅក្រៅប្រទេស | សរុប | ប្រុស | ស្រី |
|---|---|---|---|
| ប្តូរកន្លែងការងារ | 2 | 1 | 1 |
| ស្វែងរកការងារធ្វើ | 248 | 157 | 91 |
| ការសិក្សា | 1 | 0 | 1 |
| ទៅលេងសាច់ញ្ញាតិ | 1 | 1 | 0 |
| មូលហេតុផ្សេងៗ | 16 | 12 | 4 |
| សរុប | 268 | 171 | 97 |

### រូបភាព ៣.៥ ភាគរយសមាជិកចំណាកស្រុកតាមមូលហេតុ



### ៣.១.៤ ការចូលរួមកម្លាំងពលកម្ម

#### ក. វិស័យសេដ្ឋកិច្ច

តារាង ៣.៨ បង្ហាញអំពីការចូលរួមកម្លាំងពលកម្មរបស់សមាជិកគ្រួសារទៅតាមវិស័យសេដ្ឋកិច្ច នៅខេត្តគោលដៅនីមួយៗ ។ ទិន្នន័យនេះគឺទទួលបានពីការផ្តល់ចម្លើយពីមេភូមិពេលចុះសម្ភាសន៍ ដែលបង្ហាញថាចាប់តាំងពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៨ ការចូលរួមកម្លាំងពលកម្មក្នុងវិស័យកសិកម្ម បានថយប្រហែល ៤ ភាគរយ វិស័យឧស្សាហកម្មកើនជាង ៣ ភាគរយ និង វិស័យសេវាកម្មកើនជិត ១ ភាគរយ ។ ខេត្តសៀមរាបជាខេត្តមានសមាជិកចូលរួមកម្លាំងពលកម្មលើវិស័យកសិកម្មតិចជាងគេ តែវិស័យសេវាកម្មខ្ពស់ជាងគេវិញ ខណៈដែលខេត្តផ្សេងទៀតមានសមាជិកចូលរួមកម្លាំងពលកម្មលើវិស័យកសិកម្ម នៅតែមានចំនួនច្រើន។

**តារាង ៣.៨ ភាគរយការចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចតាមបណ្តាខេត្តគោលដៅ**

| ឈ្មោះខេត្ត | កសិកម្ម | | | ឧស្សាហកម្ម | | | សេវាកម្ម | | |
|---|---|---|---|---|---|---|---|---|---|
| | 2016 | 2017 | 2018 | 2016 | 2017 | 2018 | 2016 | 2017 | 2018 |
| កំពង់ឆ្នាំង | 78.7 | 76.7 | 70.7 | 15.7 | 17.0 | 20.3 | 5.7 | 6.3 | 9.0 |
| ពោធិ៍សាត់ | 84.3 | 81.7 | 78.3 | 7.7 | 9.0 | 11.0 | 8.0 | 9.3 | 10.7 |
| បាត់ដំបង | 70.0 | 66.0 | 63.3 | 13.3 | 19.0 | 18.0 | 16.7 | 16.7 | 18.7 |
| សៀមរាប | 30.3 | 28.7 | 27.0 | 11.7 | 13.7 | 15.0 | 58.0 | 57.7 | 58.0 |
| កំពង់ធំ | 61.7 | 63.3 | 65.0 | 23.3 | 23.3 | 25.0 | 15.0 | 15.0 | 10.0 |
| **សរុប** | **65.0** | **63.3** | **60.9** | **14.3** | **16.4** | **17.9** | **20.7** | **21.0** | **21.3** |

**រូបភាព ៣.៦ ភាគរយការចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច**



តារាង ៣.៩ បង្ហាញអំពីចំនួនសមាជិកចូលរួមកម្លាំងពលកម្មក្នុងវិស័យសេដ្ឋកិច្ច តាមការផ្ដល់ចម្លើយពីមេគ្រួសារនៅក្នុងខេត្តគោលដៅទាំង ៥ ក្នុងចំណោម ១.៥០០ គ្រួសារដែលបានសម្ភាសន៍។ តាមទិន្នន័យនេះ ឃើញថាចំនួនសមាជិកសរុបជាង ៥៧ ភាគរយ បានចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចក្នុងចំណោមសមាជិកអចិន្ត្រៃយ៍សរុប ៧.៤២៥នាក់ ក្នុងនោះការចូលរួមក្នុងវិស័យកសិកម្មដាំដំណាំ ចិញ្ចឹមសត្វ និង នេសាទ មានចំនួន២.០៧៨ នាក់ (៤៨,៧%) វិស័យឧស្សាហកម្ម ៧៧០ នាក់ (១៨%) និង វិស័យសេវាកម្ម ១.៤១៩នាក់ (៣៣,៣%) សម្រាប់សមាជិកទាំងពីរភេទ។ សមាជិកភេទប្រុសបានចូលរួមកម្លាំងពលកម្មក្នុងវិស័យកសិកម្មមានចំនួន ១.២១០ នាក់ (៥២,៤%) ច្រើនជាង សមាជិកភេទស្រីដែលមានចំនួន ៨៦៨នាក់ (៤៤,៣%) និងវិស័យឧស្សាកម្មសមាជិកភេទប្រុសមានចំនួន ៤៧០នាក់ (២០,៤%) ច្រើនជាងភេទស្រីដែលមានចំនួន ៣០០នាក់ (១៥,៣%) ប៉ុន្តែផ្ទុយទៅវិញ សមាជិកភេទស្រីគឺបានចូលរួមកម្លាំងពលកម្មក្នុងវិស័យសេវាកម្មមានចំនួន ៧៩០ នាក់ (៤០,៣%) ច្រើនជាងសមាជិកភេទប្រុសមានចំនួន ៦២៩នាក់(២៧,២%)។

**តារាង ៣.៩ ចំនួនសមាជិកគ្រួសារចូលរួមកម្លាំងពលកម្មក្នុងវិស័យសេដ្ឋកិច្ច**

| ការចូលរួមកម្លាំងពលកម្ម តាមវិស័យសេដ្ឋកិច្ច | ប្រុស | ស្រី | ទាំងពីរភេទ |
|---|---|---|---|
| កសិកម្មដាំដំណាំ និងចិញ្ចឹមសត្វ | 884 | 747 | 1,631 |
| កសិកម្មនេសាទ | 326 | 121 | 447 |
| ឧស្សាហកម្ម | 470 | 300 | 770 |
| សេវាកម្ម | 629 | 790 | 1,419 |
| **សរុប** | **2,309** | **1,958** | **4,267** |

**រូបភាព ៣.៧ ភាគរយការចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច**



### ក. ផ្នែកការងារ

តារាង ៣.១០ បង្ហាញពីចំនួនសមាជិកគ្រួសារដែលបានចូលរួមកម្លាំងពលកម្មតាមផ្នែកការងារ។ ទិន្នន័យនេះ ឃើញថាសមាជិកភាគច្រើនលើសលប់ បានចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យឯកជន ប្រហែល ៩៧ ភាគរយ ទាំងផ្នែកឯកជនខ្មែរ និងផ្នែកឯកជនបរទេស នៅក្នុងនោះផ្នែកឯកជនខ្មែរមានចំនួន ៣.៥៧៦នាក់ (៨៣,៨%) និងផ្នែកឯកជនបរទេស ៥៧៦នាក់ (១៣,៥%) ខណៈដែលការងារផ្នែករដ្ឋាភិបាលមានត្រឹមតែ ៨៨ នាក់(២,១%) និងផ្នែកការងារដទៃទៀតមានចំនួនតិចតួច។

**តារាង ៣.១០ ចំនួនសមាជិកគ្រួសារចូលរួមកម្លាំងពលកម្មតាមផ្នែកការងារ**

| ផ្នែកការងារ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| រដ្ឋាភិបាល | 53 | 35 | 88 |
| អង្គភាពស្វយ័ត | 2 | 0 | 2 |
| ផ្នែកឯកជនខ្មែរ | 1,959 | 1,617 | 3,576 |
| ផ្នែកឯកជនបរទេស | 287 | 289 | 576 |
| ស្ថាប័នមិនទទួលប្រាក់ចំណូល | 5 | 0 | 5 |
| ផ្នែកគ្រួសារ | 3 | 15 | 18 |
| ស្ថានទូត/ស្ថាប័នអន្តរជាតិ និងភ្នាក់ងារអភិវឌ្ឍន៍ផ្សេងៗ | 0 | 2 | 2 |
| **សរុប** | **2,309** | **1,958** | **4,267** |

## ៣.២ បរិស្ថាន
### ៣.២.១ បង្គន់អនាម័យ

តារាង ៣.១១ ចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ពីឆ្នាំ ២០១៧ ដល់ឆ្នាំ ២០១៩ ក្នុងចំណោមគ្រួសារសរុប ១.៥០០ គ្រួសារ។ តាមទិន្នន័យនេះ បង្ហាញថាចំនួនគ្រួសារមានបង្គន់អនាម័យបានកើនឡើងពី ៧៨៨គ្រួសារ (៥២,៣%)នៅឆ្នាំ ២០១៧ ទៅ ៨៤០ គ្រួសារ (៥៦%) នៅឆ្នាំ ២០១៩ ខណៈដែលគ្រួសារពុំមានបង្គន់អនាម័យប្រើប្រាស់ជាង ៤០ភាគរយទៀតពីឆ្នាំ ២០១៧ ដល់ឆ្នាំ ២០១៩។

តារាង ៣.១១ ចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់

| អធិប្បាយ | ២០១៧ | | ២០១៨ | | ២០១៩ | | សរុប |
|---|---|---|---|---|---|---|---|
| | មាន | គ្មាន | មាន | គ្មាន | មាន | គ្មាន | |
| ចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | 788 | 712 | 824 | 676 | 840 | 660 | 1,500 |

រូបភាព ៣.៨ ភាគរយគ្រួសារមានបង្គន់អនាម័យប្រើប្រាស់




## ៣.២.២ សេវាប្រមូលសំរាម ទីតាំងទុកដាក់សំរាម និងផលប៉ះពាល់ពីការចាក់សំរាម

តារាង ៣.១២ បង្ហាញអំពីចំនួនគ្រួសារមានសេវាប្រមូលសំរាម ទីតាំងចាក់សំរាម និងទទួលរងផលប៉ះពាល់ពីការចាក់សំរាម ។ តាមទិន្នន័យនេះបង្ហាញថា ចំនួនគ្រួសារមានសេវាប្រមូលសំរាមមានចំនួន ៧២គ្រួសារ(៤,៨%) ឆ្នាំ ២០១៧ និងកើនឡើងបន្តិចគឺ ៧៤ គ្រួសារ (៤,៩%) ។ គ្រួសារដែលមានទីតាំងចាក់សំរាមមានចំនួន ១៨២គ្រួសារ(១២,១%) ឆ្នាំ ២០១៧ និង កើនឡើងបន្តិច ១៨៧ គ្រួសារ(១២,៣%) ឆ្នាំ ២០១៩ ខណៈដែលទីតាំងដាក់សំរាមក្នុងបរិវេណផ្ទះរបស់គ្រួសារមានចំនួន ៨៦៣គ្រួសារ(៥៧,៥%) ឆ្នាំ ២០១៧ និង កើនឡើងបន្តិចចំនួន ៨៦៩គ្រួសារ (៥៧,៩%) នៅឆ្នាំ២០១៩។ ចំពោះគ្រួសារដែលទទួលរងផលប៉ះពាល់ពីការចាក់សំរាមមានចំនួន ៥១១គ្រួសារ (៣៤,១%) និងកើនឡើងបន្តិចផងដែរចំនួន ៥១៥គ្រួសារ (៣៤,៣%) ។

### តារាង ៣.១២ ចំនួនគ្រួសារមានសេវាប្រមូលសំរាម ទីតាំងចាក់សំរាម និងទទួលរងផលប៉ះពាល់ពីការចាក់សំរាម

| អធិប្បាយ | ២០១៧ | | ២០១៨ | | ២០១៩ | | សរុប |
|---|---|---|---|---|---|---|---|
| | មាន | គ្មាន | មាន | គ្មាន | មាន | គ្មាន | |
| សេវាកម្មប្រមូលសំរាម | 72 | 1,428 | 73 | 1,427 | 74 | 1,426 | 1,500 |
| ទីតាំងចោលសំរាម | 182 | 1,318 | 184 | 1,316 | 187 | 1,313 | 1,500 |
| ទីតាំងដាក់សំរាមក្នុងបរិវេណផ្ទះ | 863 | 637 | 869 | 631 | 869 | 631 | 1,500 |
| ផលប៉ះពាល់ពីការចាក់សំរាម | 511 | 989 | 512 | 988 | 515 | 985 | 1,500 |

### រូបភាព ៣.៩ ភាគរយគ្រួសារមានសេវាប្រមូលសំរាម ទីតាំងចាក់សំរាម និងទទួលរងផលប៉ះពាល់ពីការចាក់សំរាម



### ៣.២.៣ ផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្មឬរោងចក្រ ការបង្ហូរកាកសំណល់ចូលក្នុងទឹក និងការបាញ់ថ្នាំសម្លាប់សត្វល្អិត

តារាង ៣.១៣ បង្ហាញឲ្យឃើញថា ចំនួនគ្រួសារដែលទទួលរងផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្ម ឬ រោងចក្រ មានចំនួន ១០គ្រួសារ (០,៧%) នៅឆ្នាំ ២០១៧ និង ថយចុះបន្តិចមានចំនួន ៩គ្រួសារ (០,៦%) នៅឆ្នាំ ២០១៩ ហើយផលប៉ះពាល់ការបង្ហូរកាកសំណល់ និង ផលប៉ះពាល់ដោយការបាញ់ថ្នាំសម្លាប់សត្វល្អិតក៏មានការថយចុះផងដែរ។

**តារាង ៣.១៣ ចំនួនគ្រួសារទទួលរងផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្ម ឬ រោងចក្រ ការបង្ហូរកាកសំណល់ចូលក្នុងទឹក និងការបាញ់ថ្នាំសម្លាប់សត្វល្អិត**

| អធិប្បាយ | 2017 | | 2018 | | 2019 | | សរុប |
|---|---|---|---|---|---|---|---|
| | មាន | គ្មាន | មាន | គ្មាន | មាន | គ្មាន | |
| ផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្ម/រោងចក្រ | 10 | 1,490 | 9 | 1,491 | 9 | 1,491 | 1,500 |
| ផលប៉ះពាល់ការបង្ហូរកាកសំណល់ក្នុងទឹក | 123 | 1,377 | 118 | 1,382 | 114 | 1,386 | 1,500 |
| ផលប៉ះពាល់ថ្នាំសម្លាប់សត្វល្អិត | 477 | 1,023 | 473 | 1,027 | 473 | 1,027 | 1,500 |

**រូបភាព ៣.១០ភាគរយគ្រួសារទទួលរងផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្ម ឬ រោងចក្រ ការបង្ហូរកាកសំណល់ចូលក្នុងទឹក និងការបាញ់ថ្នាំសម្លាប់សត្វល្អិត**



### ៣.២.៤ ផលប៉ះពាល់ដោយការកាប់បំផ្លាញព្រៃឈើ និងព្រៃលិចទឹក

តារាង ៣.១៤ បង្ហាញថា គ្រួសារដែលទទួលរងគ្រោះដោយការកាប់បំផ្លាញព្រៃឈើមានចំនួន ៣១២គ្រួសារ(២១,៩%) នៅឆ្នាំ ២០១៧ និង បានកើនឡើងដល់ ៣២២គ្រួសារ(២២,៣%) នៅឆ្នាំ ២០១៩ ខណៈដែលគ្រួសារទទួលរងគ្រោះដោយការកាប់បំផ្លាញព្រៃលិចទឹកក៏មានកើនឡើងផងដែរ។

**តារាង ៣.១៤ ចំនួនគ្រួសារដែលរងដោយការកាប់បំផ្លាញព្រៃឈើ និង ព្រៃលិចទឹក**

| អធិប្បាយ | 2017 | | 2018 | | 2019 | | សរុប |
|---|---|---|---|---|---|---|---|
| | មាន | គ្មាន | មាន | គ្មាន | មាន | គ្មាន | |
| ការកាប់បំផ្លាញព្រៃឈើ | 312 | 1,188 | 320 | 1,180 | 322 | 1,178 | 1,500 |
| ការកាប់បំផ្លាញព្រៃលិចទឹក | 329 | 1,171 | 332 | 1,168 | 335 | 1,165 | 1,500 |
| ផ្សេងៗ | 8 | 1,492 | 7 | 1,493 | 8 | 1,492 | 1,500 |

**រូបភាព ៣.១១ ភាគរយគ្រួសារទទួលរងប៉ះពាល់ដោយការកាប់បំផ្លាញព្រៃឈើ និងព្រៃលិចទឹក**



## ៣.៣ គ្រោះមហន្តរាយ

គ្រោះមហន្តរាយគឺសំដៅទៅលើគ្រោះមហន្តរាយកើតឡើងដោយធម្មជាតិមានដូចជា ខ្យល់ព្យុះ រន្ទះបាញ់ ទឹកជំនន់ គ្រោះរាំងស្ងួត បាក់ច្រាំងទន្លេ ឬ ស្ទឹង ព្រែកជាដើម។ រូបភាព ៣.១២ បង្ហាញថា ចំនួនគ្រួសារដែលទទួលរងគ្រោះមហន្តរាយមានចំនួន ២៧៤គ្រួសារ ខូចខាតផ្ទះចំនួន ២៥៦ខ្នង មានសមាជិករងគ្រោះធ្ងន់ធ្ងរ ៥ នាក់ និងខូចខាតរថយន្តចំនួន ៧ គ្រឿង នៅក្នុងឆ្នាំ ២០១៩ ក្នុងពេលចុះសម្ភាសន៍ក្នុងចំណោមគ្រួសារ១.៥០០ គ្រួសារនៃខេត្តទាំង៥។

**រូបភាព ៣.១២ គ្រួសារទទួលរងគ្រោះមហន្តរាយ**




### ៣.៣.១ ទទួលរងគ្រោះដោយសាររន្ទះបាញ់

រូបភាព៣.១៣ បង្ហាញឲ្យឃើញថា ចំនួនគ្រួសារដែលទទួលរងគ្រោះដោយសាររន្ទះបាញ់មានចំនួន ១៣ គ្រួសារ និងស្លាប់គោក្របីចំនួន ៨ ក្បាលនៅឆ្នាំ ២០១៩ នៅក្នុងចំណោមគ្រួសារ ១.៥០០ គ្រួសារដែលបានផ្តល់ចម្លើយ នៅក្នុងពេលចុះសម្ភាសន៍ស្រង់ទិន្នន័យតាមខេត្តគោលដៅដែលបានកំណត់។

រូបភាព ៣.១៣ ចំនួនគ្រួសារ និងចំនួនគោក្របីដែលទទួលរងគ្រោះដោយសាររន្ទះបាញ់




## ៣.៣.២ ទទួលរងគ្រោះដោយសារទឹកជំនន់

រូបភាព ៣.១៤ បង្ហាញឲ្យឃើញថា ចំនួនគ្រួសារដែលទទួលរងគ្រោះដោយសារទឹកជំនន់ មានចំនួន ៣៨០ គ្រួសារ ក្នុងនោះខូចខាតដំណាំអស់ចំនួន ២៨១ គ្រួសារ ខូចខាតផ្ទះចំនួន ៩៤ ខ្នង និងប៉ះពាល់ដល់សត្វពាហនៈចំនួន ៦៩ ក្បាល និងមានការខូចខាតសម្ភារៈផ្សេងៗចំនួន ១១ គ្រួសារ ។

រូបភាព ៣.១៤ គ្រួសារដែលទទួលរងគ្រោះដោយសារទឹកជំនន់




## ៣.៣.៣ ទទួលរងគ្រោះរាំងស្ងួត

រូបភាព ៣.១៥ បង្ហាញឲ្យឃើញថា ចំនួនគ្រួសារដែលទទួលរងគ្រោះរាំងស្ងួតមានចំនួន ៥៩០ គ្រួសារ ខ្វះទឹកប្រើប្រាស់ក្នុងគ្រួសារ ៣៥៥ គ្រួសារ ខូចខាតដំណាំ ៤៦៥ គ្រួសារ ប៉ះពាល់ដល់សត្វពាហនៈចំនួន ១០៨ ក្បាល និង ខូចខាតសម្ភារៈផ្សេងៗមានចំនួន ៤ គ្រួសារ នៅក្នុងចំណោម ១.៥០០ គ្រួសារ ដែលបានចុះសម្ភាសន៍ស្រង់ទិន្នន័យក្នុងឆ្នាំ ២០១៩ ។

រូបភាព ៣.១៥ គ្រួសារទទួលរងគ្រោះរាំងស្ងួត




## ៣.៣.៤ ទទួលរងគ្រោះដោយសារការបាក់ច្រាំងទន្លេ ស្ទឹង ព្រែក

រូបភាព ៣.១៦ បង្ហាញថា ចំនួនគ្រួសារបាក់ច្រាំងទន្លេមានចំនួន ២៣ គ្រួសារ ខូចខាតសម្ភារៈ ២១ គ្រួសារ បាត់បង់ផ្ទះសម្បែងចំនួន ២គ្រួសារ និងបាត់បង់អាយុជីវិតសមាជិកនៅក្នុងគ្រួសារមានចំនួន ២ គ្រួសារ ក្នុងចំណោមគ្រួសារទាំង ១.៥០០ គ្រួសារដែលបានចុះសម្ភាសន៍។

## រូបភាព ៣.១៦ គ្រួសាររងគ្រោះដោយសារបាក់ច្រាំង




# ៣.៤ ការប្រែប្រួលអាកាសធាតុ

## ៣.៤.១ ស្ថានភាពទឹកភ្លៀង

តារាង ៣.១៥ បង្ហាញឲ្យឃើញថា ស្ថានភាពភ្លៀងធ្លាក់តាមការចំណាំរបស់ប្រជាជនដែលបានផ្ដល់ចម្លើយអំឡុងពេលសម្ភាសន៍គឺ មានចំនួនមេគ្រួសារ ២៩៣ នាក់ (១៩,៥%) បានឆ្លើយថា មានភ្លៀងទៀងទាត់ ហើយមានចំនួនមេគ្រួសារ ៧៥០ នាក់ (៥០%) ឆ្លើយថាភ្លៀងមិនទៀងទាត់ និងចំនួនមេគ្រួសារឆ្លើយថាភ្លៀងធ្លាក់ទៀងទាត់ខ្លះ មិនទៀងទាត់ខ្លះមានចំនួន ៤៥៧ នាក់ (៣០,៥%) ។ តាមទិន្នន័យនេះបានបញ្ជាក់ច្បាស់ថា ភ្លៀងធ្លាក់មិនទៀងទាត់ គឺមានភាគរយខ្ពស់ជាងគេ តាមការកត់ចំណាំរបស់ពួកគាត់ ។

### តារាង ៣.១៥ ស្ថានភាពទឹកភ្លៀង

| អធិប្បាយ | ចំនួនមេគ្រួសារបានឆ្លើយ | ចំនួនគ្រួសារសរុប |
|---|---|---|
| ភ្លៀងធ្លាក់ទៀងទាត់ | 293 | 1,500 |
| ភ្លៀងធ្លាក់មិនទៀងទាត់ | 750 | 1,500 |
| ភ្លៀងធ្លាក់ទៀងទាត់ខ្លះ មិនទៀងទាត់ខ្លះ | 457 | 1,500 |

### រូបភាព ៣.១៧ ស្ថានភាពទឹកភ្លៀង



## ៣.៤.២ ស្ថានភាពសីតុណ្ហភាព

តារាង ៣.១៦ បង្ហាញថាចំនួនមេគ្រួសារ ៦៤០ នាក់ (៤២,៧%) បានឆ្លើយថា សីតុណ្ហភាពមានកម្តៅខ្លាំង ខណៈដែលចំនួនមេគ្រួសារ ៧៩៧ នាក់ (៥៣%) ឆ្លើយថាសីតុណ្ហភាពមានកម្តៅល្មមអាចទ្រាំទ្របាន ចំនួនមេគ្រួសារ ៤២នាក់(២,៨%) ឆ្លើយថា ត្រជាក់ល្មម និងចំនួនមេគ្រួសារ ២១ នាក់(១,៤%) ឆ្លើយថា ត្រជាក់ខ្លាំង ។ តាមទិន្នន័យ យើងអាចបញ្ជាក់ថាសីតុណ្ហភាពមានការប្រែប្រួលខុសពីមុនតាមការកត់សំគាល់របស់ពួកគាត់។

**តារាង ៣.១៦ ស្ថានភាពសីតុណ្ហភាព**

| សីតុណ្ហភាព | ចំនួនមេគ្រួសារបានឆ្លើយ | ភាគរយ |
|---|---|---|
| ក្តៅខ្លាំង | 640 | 42.7 |
| ក្តៅល្មម | 797 | 53.1 |
| ត្រជាក់ខ្លាំង | 21 | 1.4 |
| ត្រជាក់ល្មម | 42 | 2.8 |

**រូបភាព ៣.១៨ ស្ថានភាពសីតុណ្ហភាព**



# ជំពូក ៤
# បញ្ហាប្រឈម របកគំហើញ
# ដំណោះស្រាយ និង សន្និដ្ឋាន

## ៤.១ បញ្ហាប្រឈម

នៅក្នុងការអនុវត្តគម្រោងអង្កេតកពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩ ដែលបានឧបត្ថម្ភថវិកាដោយរាជរដ្ឋាភិបាលកម្ពុជា អង្គភាពក្រុមសង្កេតការណ៍ភពផែនដី ដែលស្ថិតនៅក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានជួបបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

### ៤.១ .១ សម្ភារៈ និង ឧបករណ៍បច្ចេកទេស

- នៅក្នុងការចុះស្រង់ទិន្នន័យនៅប្រទេសផ្សេងគេប្រើផ្កាយរណប ថតតាមយន្តហោះ និងតាមឧបករណ៍ដែលអាចថតពីលើអាកាសបានដូចជា ដ្រូន ដែលគេនិយមប្រើនាពេលបច្ចុប្បន្ន ។ ដូច្នេះដោយសារតែប្រទេសយើងពុំមានផ្កាយរណប និងឧបករណ៍សម្រាប់ថតរូបភាពតាមអាកាស នៅពេលចុះស្រង់ទិន្នន័យតាមគោលដៅដែលចង់បាន ក្រុមការងាររបស់អង្គភាពក្រុមសង្កេតការភពផែនដីបានប្រើវិធីចុះសម្ភាសន៍តាមមេភូមិ និងមេគ្រួសារតាមរយៈកម្រងសំណួរ ដើម្បីទទួលបានចម្លើយតាមអ្វីពួកគាត់បានកត់សំគាល់ទាក់ទងទៅនឹងបរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុជាដើម។ បើទោះបីជា វិធីសាស្ត្រនៃការប្រមូលទិន្នន័យនេះជាវិធីសាស្ត្រចាស់ក៏ពិតមែន តែគេអាចជឿទុកចិត្តបានពី៦០ ទៅ ៧០ភាគរយផងដែរ។

- ខ្វះមធ្យោបាយធ្វើដំណើរដូចជារថយន្ត ដោយសារតែកិច្ចការងារនេះត្រូវចុះសិក្សាស្រាវជ្រាវដល់ទីតាំងតាមបណ្តាខេត្តផ្សេងៗទាក់ទងទៅនឹងការងារបរិស្ថាន គ្រោះមហន្តរាយ និង ការប្រែប្រួលអាកាសធាតុ។

- ខ្វះកុំព្យូទ័រ និងកៅអីសម្រាប់ធ្វើការងារនៅការិយាល័យពុំគ្រប់គ្រាន់ ខណៈដែលមានបន្ទប់ការិយាល័យធ្វើការងាររួចហើយ។

### ៤.១.២ ទីប្រឹក្សាអន្តរជាតិ និងថវិកា

- ខ្វះទីប្រឹក្សា ឬ អ្នកជំនាញការអន្តរជាតិ ជួយណែនាំបង្ហាត់បង្ហាញអំពីរបៀបធ្វើការងារដោយសារការងារនេះថ្មី ហើយមន្ត្រីដែលចូលរួមកិច្ចការងារនេះពុំទាន់មានបទពិសោធន៍នៅឡើយ។ កន្លងមក អង្គភាពក្រុមសង្កេតការណ៍ភពផែនដីបានស្នើឲ្យប្រទេសអូស្ត្រាលីជួយបង្កើតទិន្នន័យគូបតាមលិខិតស្នើសុំតាមរយៈស្ថានទូតអូស្ត្រាលីប៉ុន្តែពុំមានការឆ្លើយតបនៅឡើយ។ ប្រទេសចិនកន្លងមកក៏បានសន្យាថានឹងជួយពង្រឹងសមត្ថភាពមន្ត្រីទាក់ទងការងារទាំងនេះ។

- ថវិកាដែលទទួលបានពីរាជរដ្ឋាភិបាលកម្ពុជាសម្រាប់អនុវត្តគម្រោងការងារនេះនៅមានកំណត់នៅឡើយដែលអាចប៉ះពាល់ដល់វិសាលភាពនៃការសិក្សាស្រាវជ្រាវឲ្យបានទូលំទូលាយ។

### ៤.១.៣ សមត្ថភាពមន្ត្រី

មន្ត្រីដែលចូលរួមការងារនៅក្នុងគម្រោងនេះ មានជំនាញផ្សេងៗដែលមិនសមស្របទៅនឹងជំនាញដែលត្រូវអនុវត្តការងារជាក់ស្តែង ប៉ុន្តែពួកគាត់មានឆន្ទៈការងារខ្ពស់ និងបទពិសោធន៍ក្នុងការចុះស្រង់ទិន្នន័យតាមរយៈគម្រោងផ្សេងៗជាយូរមកហើយ។

## ៤.២ របកគំហើញ

តាមរយៈការសិក្សាស្រាវជ្រាវ នៅក្នុងគម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩ នៅតាមខេត្តគោលដៅទាំង ៥ គឺ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ ដែលផ្អែកលើទិន្នន័យទី២ ដែលទទួលបានពីប្រភពផ្សេងៗ និងទិន្នន័យទី១ ដោយការចុះសម្ភាសន៍ផ្ទាល់ដល់ទីតាំងជាក់ស្តែងបានបង្ហាញអំពីរបកគំហើញដូចខាងក្រោម៖

### ៤.២.១ កំណើនប្រជាជន និង ការធ្វើចំណាកស្រុក

កំណើនប្រជាជនមានការកើនឡើងជាលំដាប់នៅទូទាំងប្រទេស រួមទាំងតំបន់ដែលស្ថិតនៅជាប់បឹងទន្លេសាបផងដែរ។ សមាជិកក្នុងគ្រួសារភាគច្រើនបានធ្វើចំណាកស្រុកពីខេត្តមួយទៅខេត្តមួយផ្សេងទៀត ដើម្បីស្វែងរកការងារធ្វើ និងចំណាកស្រុកទៅក្រៅប្រទេសក៏ដើម្បីស្វែងរកការងារធ្វើផងដែរ។ ការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យកសិកម្មមានការថយចុះ ប៉ុន្តែការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យឧស្សាហកម្ម និងវិស័យសេវាកម្មមានការកើនឡើងជាលំដាប់។

### ៤.២.២ តំបន់ទីប្រជុំជនមានការកើនឡើង

ចំនួនប្រជាជនដែលរស់នៅតំបន់ទីប្រជុំជនមានការកើនឡើងជាលំដាប់ចាប់តាំងពីឆ្នាំ ១៩៩៨ មកទល់បច្ចុប្បន្ន និងម្យ៉ាងទៀតរាជរដ្ឋាភិបាលកម្ពុជា បានកែប្រែតំបន់រដ្ឋបាលមួយចំនួនស្របតាមការអភិវឌ្ឍរបស់ប្រទេស ប៉ុន្តែជាក្តីបារម្ភផងដែរ ទាក់ទងទៅនឹងសន្តិសុខស្បៀងសម្រាប់ប្រទេសកម្ពុជា ដោយសារដីដែលផលិតដំណាំកសិកម្ម និងដាំណាំស្រូវត្រូវបានបង្វែរសង់លំនៅដ្ឋាន និងធ្វើការអភិវឌ្ឍផ្សេងៗ។

### ៤.២.៣ បរិស្ថាន

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវបានរកឃើញថា បញ្ហាប្រមូលសំរាម ការទុកដាក់សំរាម ការប្រើប្រាស់ទឹកស្អាត និងការប្រើប្រាស់បង្គន់អនាម័យរបស់ប្រជាជននៅមានកម្រិតនៅឡើយ។ លើសពីនេះទៀត ការកាប់បំផ្លាញព្រៃឈើ ការកាប់បំផ្លាញព្រៃលិចទឹក ការបង្ហូរកាកសំណល់របស់រោង

សិប្បកម្ម និងរោងចក្រទៅក្នុងទន្លេ ស្ទឹង ព្រែក ឬ បឹងធម្មជាតិ បានធ្វើឲ្យប៉ះពាល់ការរស់នៅរបស់ប្រជាជន និងសំណង់លំនៅដ្ឋានមានការកើនឡើង ដែលតម្រូវឲ្យមានការគ្រប់គ្រងបរិស្ថានឲ្យបានល្អ។

### ៤.២.៤ គ្រោះមហន្តរាយ

គ្រោះមហន្តរាយធម្មជាតិដូចជាគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត រន្ទះបាញ់ ខ្យល់ព្យុះ និងបាក់ច្រាំងទន្លេគឺពិតជាបានកើតឡើងប្រាកដមែន តាមរយៈនៃកាសិក្សានេះ។ នៅក្នុងនោះគ្រោះមហន្តរាយធម្មជាតិដែលបណ្ដាលឲ្យស្លាប់ច្រើនជាងគេគឺគ្រោះមហន្តរាយទឹកជំនន់ បន្ទាប់មករន្ទះបាញ់ និង ខ្យល់ព្យុះមានចំនួនតិចជាងគេ ខណៈដែលគ្រោះមហន្តរាយផ្សេងទៀតពុំមានអ្នកស្លាប់តែបង្កគ្រោះថ្នាក់ និងខូចខាតសម្ភារៈ។

### ៤.២.៥ ការប្រែប្រួលអាកាសធាតុ

បើទោះបី ការអនុវត្តគម្រោងនេះពុំមានឧបករណ៍ទំនើបសម្រាប់ស្រង់ទិន្នន័យតាមរយៈផ្កាយរណប ឬ ដ្រូនពិតមែន តែតាមរយៈការសិក្សាស្រាវជ្រាវនៃប្រភពទិន្នន័យផ្សេងៗ និងការចុះសម្ភាសន៍ស្រង់ទិន្នន័យផ្ទាល់ដល់មូលដ្ឋានជាក់ស្តែងរកឃើញថាៈ

- កំពស់ទឹកមានការថយចុះ
- ភ្លៀងធ្លាក់មិនទៀងទាត់
- សីតុណ្ហភាពមានការប្រែប្រួលជាពិសេសមានកម្ដៅខ្លាំងខុសពីប្រក្រតី។

## ៤.៣ ដំណោះស្រាយ

តាមរយៈការលើកឡើងពីបញ្ហាប្រឈម និងរបកគំហើញដែលបានរកឃើញនៅពេលចុះសិក្សាស្រាវជ្រាវតាមរយៈការអនុវត្តគម្រោងការងារនេះ គួរតែមានដំណោះស្រាយ និងវិធានការណ៍មួយចំនួនដូចខាងក្រោម៖

- ពង្រឹងសមត្ថភាពមន្ត្រីឲ្យមានសមត្ថភាពកាន់តែប្រសើរឡើង និង ដោះស្រាយបញ្ហាប្រឈមដែលបានលើកឡើងតាមដែលអាចធ្វើបាន
- បង្កើតការងារក្នុងប្រទេសឲ្យបានច្រើនទាំងការងារកសិកម្ម ឧស្សាហកម្ម និងសេវាកម្មជៀសវាងការធ្វើចំណាកស្រុកពីខេត្តមួយទៅខេត្តមួយ និងទៅក្រៅប្រទេស
- ថែរក្សាឲ្យបាននូវដីដែលមានសក្ដានុពលកសិកម្មសម្រាប់ជាសន្តិសុខស្បៀងយូរអង្វែង ដោយសារតែការកើនឡើងតំបន់ទីប្រជុំជន និងសំណង់លំនៅដ្ឋានមានការកើនឡើង

- អប់រំប្រជាជនឲ្យស្វែងយល់អំពីការប៉ះពាល់បរិស្ថានឲ្យបានស៊ីជម្រៅ និង រកវិធីសាស្ត្រយ៉ាងណាការពារ ឬកែឆ្នៃកាកសំណល់រឹងនិងរាវដែលបណ្ដាលមកពីរោងសិប្បកម្ម និងរោងចក្រ កុំឲ្យប៉ះពាល់សុខភាពដល់បរិស្ថានការរស់នៅរបស់ប្រជាជនទូទៅ
- រៀបចំប្រព័ន្ធផ្ដល់ព័ត៌មាន ឬ វិធីសាស្ត្របង្ការគ្រោះមហន្តរាយដែលអាចកើតឡើងដូចជាគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ រន្ទះបាញ់ និងការបាក់ច្រាំងជាដើម
- រៀបចំវិធីសាស្ត្របង្ការដែលទាក់ទងទៅនឹងការប្រែប្រួលអាសកាសធាតុមានដូចជា សីតុណ្ហភាពមានការកើនឡើងកម្ដៅខ្លាំង និងត្រជាក់ខ្លាំងជាដើម។

## ៤.៤ សន្និដ្ឋាន

តាមរយៈលទ្ធផលនៃអង្កេតកពផែនដីនៅព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ ២០១៩ នៅក្នុងខេត្ត ៥ ជាប់បឹងទន្លេសាប ដោយផ្អែកលើសូចនាករទាំងឡាយដែលប្រមូលបានពីប្រភពផ្សេងៗ និងការចុះសម្ភាសន៍ផ្ទាល់អាចសន្និដ្ឋានបានថា បញ្ហាប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុពិតជាបានកើតឡើងនៅក្នុងតំបន់ដែលស្ថិតនៅក្នុងក្របខណ្ឌនៃធ្វើអង្កេតនេះ ពិតប្រាកដមែន ដែលត្រូវរៀបចំគោលនយោបាយ និងផែនការសកម្មភាពសម្រាប់មានវិធានការបង្ការផ្សេងៗ។ នៅក្នុងផ្នែកគ្រោះមហន្តរាយ គឺពុំមានទិន្នន័យអំពីគ្រោះមហន្តរាយរលកយក្សស៊ូណាមី និងរញ្ជួយដីដូចប្រទេសផ្សេងទៀតឡើយគឺមានតែគ្រោះមហន្តរាយទឹកជំនន់ គ្រោះរាំងស្ងួត រន្ទះបាញ់ ខ្យល់ព្យុះ និងការបាំងច្រាំងទន្លេ ឬ ស្ទឹង ដែលក្នុងនោះគ្រោះមហន្តរាយដែលបង្កឲ្យមានមនុស្ស និងសត្វស្លាប់ មានដូចជាគ្រោះទឹកជំនន់ រន្ទះបាញ់ និងខ្យល់ព្យុះ ខណៈដែលគ្រោះមហន្តរាយផ្សេងទៀតបង្កការខូចខាតទ្រព្យសម្បត្តិតែប៉ុណ្ណោះ។

សរុបមក លទ្ធផលនេះបានបង្ហាញអំពីសមិទ្ធិផលថ្មីមួយទៀត ដែលមិនធ្លាប់មានពីមុនមក ហើយជាទិន្នន័យដែលមានសារៈប្រយោជន៍យ៉ាងសំខាន់ដល់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការរៀបចំគោលនយោបាយជាតិ និងការធ្វើផែនការ ដែលទាក់ទងនឹងប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយផ្សេងៗ និងការប្រែប្រួលអាកាសធាតុបន្ថែមពីលើទិន្នន័យពីប្រភពផ្សេងៗទៀតដែលមានស្រាប់។

# ឯកសារយោង


១. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០០២។

២. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *របាយការណ៍ទូទៅនៃការធ្វើអង្កេតប្រជារាស្ត្រកម្ពុជាចន្លោះជំរឿនឆ្នាំ ២០០៤* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០០២។

៣. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០០៩។

៤. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣ របាយចុងក្រោយ* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០១៣។

៥. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ តួលេខបណ្ដោះអាសន្ននៃចំនួនប្រជាជនសរុប* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០១៣។

៦. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ ២០១៧* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០១៨។

៧. មន្ទីរផែនការរាជធានី ខេត្ត៖ *ទិន្នន័យមូលដ្ឋាន* ២០១៦, ២០១៧ និង ២០១៨, មន្ទីរផែនការរាជធានី ខេត្ត។

៨. National Institute of Statistics, Ministry of Planning, *General Population Census of Cambodia 2008, Analysis of the Census Results, Report 12 Population Projection of Cambodia, Phnom Penh,* National Institute of Statistics, Ministry of Planning 2011.

៩. National Institute of Statistics, Ministry of Planning, *Reclassification of Urban Areas in Cambodia 2011, Phnom Penh,* National Institute of Statistics, Ministry of Planning 2011.

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# បញ្ជីសំណួរការចុះស្រង់ទិន្នន័យ
# នៅតាមបណ្តាខេត្តជាប់បឹងទន្លេសាបសម្រាប់គាំទ្រ
# សកម្មភាពក្រុមសង្កេតការភពផែនដីរបស់ប្រទេសកម្ពុជា
# (សម្រាប់មេភូមិ)

**រៀបចំដោយ៖**

អង្គភាពក្រុមសង្កេតការភពផែនដី
វិទ្យាស្ថានជាតិស្ថិតិ
ក្រសួងផែនការ

រាជធានីភ្នំពេញ ខែ មិថុនា ឆ្នាំ ២០១៩

**១. ព័ត៌មានសម្គាល់៖**

រាជធានី/ខេត្ត...............................................

ក្រុង/ស្រុក/ខណ្ឌ...........................................

ឃុំ/សង្កាត់..................................................

ភូមិ/មណ្ឌល.................................................

ទីប្រជុំជន/ជនបទ.........................................

កាលបរិច្ឆេទចុះស្រង់ទិន្នន័យៈ ថ្ងៃទី ........ ខែ ........... ឆ្នាំ ២០១៩

ឈ្មោះមេភូមិ ......................................ភេទ ........... អាយុ.......

លេខទូរស័ព្ទមេភូមិ ...................................

ឈ្មោះមន្ត្រីសម្ភាសន៍ ...............................................

២. **ព័ត៌មានអំពីគ្រួសារក្នុងភូមិ៖**

| ល.រ | ប្រភេទទិន្នន័យ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|
| ១ | ចំនួនគ្រួសារសរុប | | | |
| ២ | ចំនួនគ្រួសារទទួលបានទឹកស្អាត | | | |
| ៣ | ចំនួនគ្រួសារដែលប្រើប្រាស់អគ្គិសនី | | | |
| ៤ | ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្ម | | | |
| ៥ | ចំនួនប្រជាជនធ្វើការក្នុងវិស័យឧស្សាហកម្ម | | | |
| ៦ | ចំនួនប្រជាជនធ្វើការក្នុងវិស័យសេវាកម្ម | | | |

៣. **ព័ត៌មានអំពីគ្រោះមហន្តរាយ ៖**

៣.១ តើមានចំនួនសម្ភារៈប៉ុន្មានដែលខូចខាត ដោយសារខ្យល់ព្យុះ ឬ ខ្យល់កន្ត្រាក់ ដែរ ឬ ទេក្នុងឆ្នាំ ២០១៨ កន្លងមក? បើគ្មាន សូមចុះលេខសូន្យ " 0 "

ក. ចំនួនផ្ទះសម្បែងដែលខូចខាត

ខ. ចំនួនយានយន្តដែលខូចខាតៈ ម៉ូតូ ឡាន

គ.ផ្សេងៗ (បញ្ជាក់)....................

៣.២ តើមានជនរងគ្រោះដោយសាររន្ទះបាញ់ប៉ុន្មាននាក់ក្នុង ២០១៨ កន្លងមក? បើគ្មាន សូមចុះលេខសូន្យ " 0 "

៣.៣ តើមានចំនួនគ្រួសារប៉ុន្មានទទួលរងគ្រោះដោយសារទឹកជំនន់ដែរ ឬ ទេក្នុងឆ្នាំ ២០១៨ កន្លងមក? បើគ្មាន សូមចុះលេខសូន្យ " ០ " ☐

៣.៤ តើមានចំនួនគ្រួសារប៉ុន្មានដែលខ្វះខាតទឹកប្រើប្រាស់ ដោយសារគ្រោះរាំងស្ងួតដែរ ឬ ទេក្នុងឆ្នាំ ២០១៨ កន្លងមក? បើគ្មាន សូមចុះលេខសូន្យ " ០ " ☐

៣.៥ តើមានចំនួនគ្រួសារប៉ុន្មានដែលធ្លាប់ទទួលរងគ្រោះដោយសារបាក់ច្រាំងទន្លេ ស្ទឹង ព្រែក ... ក្នុងឆ្នាំ ២០១៨ កន្លងមកដែរ ឬ ទេ? បើគ្មាន សូមចុះលេខសូន្យ " ០ " ☐

## ៤. ផលប៉ះពាល់បរិស្ថានក្នុងភូមិ

៤.១ ចំនួនគ្រួសារដែលទទួលរងផលប៉ះពាល់ពីកាកសំណល់ សិប្បកម្ម ឬ រោងចក្រ ☐

៤.២ ចំនួនគ្រួសារដែលរងផលប៉ះពាល់ការបង្ហូរទឹកសំអុយ ☐

## ៥. ការប្រែប្រួលអាកាសធាតុ

៥.១ តើតាមការកត់សំគាល់របស់លោកពូអ្នកមីងឃើញថាមានការប្រែប្រួលទាក់ទងនឹងអាកាសធាតុដូចម្ដេចដែរ?

| | | | | |
|---|---|---|---|---|
| ក. សីតុណ្ហភាព | ប្រែប្រួល | ☐ | មិនប្រែប្រួល | ☐ |
| ខ. ទឹកភ្លៀង | ទៀងទាត់ | ☐ | មិនទៀងទាត់ | ☐ |
| គ. គ្រោះរាំងស្ងួត | មានរាំងស្ងួត | ☐ | មិនមានរាំងស្ងួត | ☐ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# បញ្ជីសំណួរការចុះស្រង់ទិន្នន័យ
# នៅតាមបណ្ដាខេត្តជាប់បឹងទន្លេសាបសម្រាប់គាំទ្រ
# សកម្មភាពក្រុមសង្កេតការភពផែនដីរបស់ប្រទេសកម្ពុជា
# (សម្រាប់គ្រួសារ)

**រៀបចំដោយ៖**


អង្គភាពក្រុមសង្កេតការភពផែនដី

វិទ្យាស្ថានជាតិស្ថិតិ

ក្រសួងផែនការ



រាជធានីភ្នំពេញ ខែ មិថុនា ឆ្នាំ ២០១៩

**១. ព័ត៌មានសម្គាល់៖**

រាជធានី/ខេត្ត............................................... ☐☐
ក្រុង/ស្រុក/ខណ្ឌ........................................... ☐☐
ឃុំ/សង្កាត់................................................... ☐☐
ភូមិ/មណ្ឌល................................................. ☐☐
ទីប្រជុំ/ជនបទ ............................................. ☐☐
កាលបរិច្ឆេទចុះស្រង់ទិន្នន័យៈ ថ្ងៃទី ........ ខែ .......... ឆ្នាំ ២០១៩
ឈ្មោះអ្នកតបសម្ភាសន៍ ...............................................
លេខទូរស័ព្ទអ្នកតបសម្ភាសន៍ .......................................
ឈ្មោះមន្ត្រីសម្ភាសន៍ ..................................................

**២. ព័ត៌មានទូទៅអំពីគ្រួសារ៖**

**២.១ ចំនួនសមាជិកគ្រួសារ**

ឈ្មោះមេគ្រួសារ ......................................... ភេទ .......... អាយុ ...........

| សមាជិកអចិន្ត្រៃយ៍ | | | សមាជិកចំណាកស្រុក | | | ចំណាកស្រុកក្នុប្រទេស | | | ចំណាកស្រុកក្រៅប្រទេស | | |
|---|---|---|---|---|---|---|---|---|---|---|---|
| សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| | | | | | | | | | | | |

**២.១.១ មុខរបបចម្បងរបស់សមាជិកគ្រួសារក្នុងរយៈពេល ១២ ខែ កន្លងមក**

ក. ចំនួនសមាជិកក្នុងគ្រួសារធ្វើការក្នុងវិស័យកសិកម្ម (ដាំដំណាំ និងចិញ្ចឹមសត្វ) ៖
ប្រុស ☐ ស្រី ☐ សរុប ☐

ខ. ចំនួនសមាជិកក្នុងគ្រួសារធ្វើការនេសាទ៖
ប្រុស ☐ ស្រី ☐ សរុប ☐

គ. ចំនួនសមាជិកក្នុងគ្រួសារធ្វើការក្នុងវិស័យឧស្សាហកម្ម៖ ប្រុស ☐ ស្រី ☐ សរុប ☐

ឃ. ចំនួនសមាជិកក្នុងគ្រួសារធ្វើការក្នុងវិស័យសេវាកម្ម៖ ប្រុស ☐ ស្រី ☐ សរុប ☐

**២.១.២ សមាជិកគ្រួសារធ្វើការងារក្នុងផ្នែកណាមួយក្នុងរយៈពេល ១២ ខែ កន្លងមក**

ក.រដ្ឋាភិបាល ប្រុស ☐ ស្រី ☐ សរុប ☐
ខ. អង្គភាពស្វយ័ត ប្រុស ☐ ស្រី ☐ សរុប ☐
គ. ផ្នែកឯកជនខ្មែរ ប្រុស ☐ ស្រី ☐ សរុប ☐

ឃ.ផ្នែកឯកជនបរទេស ប្រុស ☐ ស្រី ☐ សរុប ☐

ង. ស្ថាប័នមិនយកប្រាក់ចំណេញ ប្រុស ☐ ស្រី ☐ សរុប ☐

ច. ផ្នែកគ្រួសារ ប្រុស ☐ ស្រី ☐ សរុប ☐

ឆ.ស្ថានទូត/ស្ថាប័នអន្តរជាតិ និងភ្នាក់ងារអភិវឌ្ឍន៍ និងជំនួយបរទេស

ប្រុស ☐ ស្រី ☐ សរុប ☐

ជ. ផ្សេងៗ..............................ប្រុស ☐ ស្រី ☐ សរុប ☐

### ២.១.៣ ចំណាកស្រុកក្នុងប្រទេស

| ឈ្មោះរាជធានី-ខេត្ត | ចំនួនសមាជិកគ្រួសារចំណាកស្រុក (ក្នុងប្រទេស) ចាប់ ៦ ខែឡើង | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |

ក. មូលហេតុចំណាកស្រុកក្នុងប្រទេស

| មូលហេតុ | ចំនួនសមាជិកចំណាកស្រុក (ក្នុងប្រទេស) | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |
| សរុប | | | |

### ២.១.៤ ចំណាកស្រុកក្រៅប្រទេស

| ឈ្មោះប្រទេស | ចំនួនសមាជិកគ្រួសារចំណាកស្រុក (ក្រៅប្រទេស) | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |

ក. មូលហេតុចំណាកស្រុកក្រៅប្រទេស

| មូលហេតុ | ចំនួនសមាជិកគ្រួសារចំណាកស្រុក (ក្រៅប្រទេស) | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |
| **សរុប** | | | |

### ២.២ មុខរបររបស់សមាជិកគ្រួសារ

| មុខរបរចម្បងៗ | ចំនួនសមាជិកគ្រួសារដែលបានចូលរួម | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |
| **សរុប** | | | |

### ៣. ព័ត៌មានបរិស្ថានអំពីគ្រួសារ

១=មាន ២=គ្មាន

| លរ | ប្រភេទប៉ះពាល់បរិស្ថាន | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|---|
| ១ | បង្គន់អនាម័យ | | | |
| ២ | សេវាប្រមូលសំរាម | | | |
| ៣ | ទីតាំងចោលសំរាម | | | |
| ៤ | ទីតាំងទុកដាក់សំរាមនៅក្នុងបរិវេណផ្ទះ | | | |
| ៥ | ផលប៉ះពាល់ពីការចោលសំរាម | | | |
| ៦ | ផលប៉ះពាល់ពីកាកសំណល់សិប្បកម្ម/រោងចក្រ | | | |
| ៧ | ផលប៉ះពាល់បង្ហូរកាកសំណល់ចូលក្នុងទឹក | | | |
| ៨ | ផលប៉ះពាល់ថ្នាំបាញ់សម្លាប់សត្វល្អិត | | | |
| ៩ | ផលប៉ះពាល់ការប្រើប្រាស់ជីគីមី | | | |
| ១០ | កាប់បំផ្លាញព្រៃឈើ | | | |
| ១១ | កាប់បំផ្លាញព្រៃលិចទឹក | | | |
| ១២ | ផ្សេងៗ (បញ្ជាក់) | | | |

### ៤. គ្រោះមហន្តរាយ

**៤.១ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារខ្យល់ព្យុះ ឬ ខ្យល់កន្ត្រាក់ ដែរ ឬ ទេក្នុងឆ្នាំ ២០១៨ កន្លងមក?**

បាទ/ចាស ☐ ទេ ☐

- បើបាទ/ចាស សូមបញ្ជាក់ពីប្រភេទនៃការទទួលរងគ្រោះ៖

ក. ខូចខាតផ្ទះសម្បែង ☐

ខ. ខូចខាតទ្រព្យសម្បត្តិ (កង់, ម៉ូតូ, ឡាន...) ☐

គ. សមាជិកគ្រួសារទទួលរងរបួស ប្រុស ☐ ស្រី ☐ សរុប ☐

ឃ. សមាជិកគ្រួសារទទួលរងគ្រោះដល់ស្លាប់ ប្រុស ☐ ស្រី ☐ សរុប ☐

ង. ផ្សេងៗសូមបញ្ជាក់(.........................................................)

**៤.២ តើសមាជិកគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសាររន្ទះបាញ់ដែរ ឬ ទេក្នុងឆ្នាំ ២០១៨ កន្លងមក?**

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៣)*

ក. សមាជិកគ្រួសារទទួលរងរបួស ប្រុស ☐ ស្រី ☐ សរុប ☐

ខ. សមាជិកគ្រួសារទទួលរងគ្រោះដល់ស្លាប់ ប្រុស ☐ ស្រី ☐ សរុប ☐

**៤.៣ តើមានសត្វពាហនៈនៅក្នុងគ្រួសារអ្នកដែលទទួលរងគ្រោះដោយសាររន្ទះបាញ់ដែរ ឬ ទេក្នុងឆ្នាំ ២០១៨ កន្លងមក?**

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៤)*

ក. ស្លាប់សត្វពាហនៈ ☐

ខ. សត្វផ្សេងៗសូមបញ្ជាក់(.......................................................) ☐

**៤.៤ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារទឹកជំនន់ដែរ ឬ ទេក្នុងឆ្នាំ ២០១៨ កន្លងមក?**

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៥)*

ក. ខូចខាតផ្ទះសម្បែង ☐

ខ. ខូចខាតដំណាំកសិកម្ម ☐

គ. ប៉ះពាល់ដល់សត្វពាហនៈ ☐

ឃ. ផ្សេងៗសូមបញ្ជាក់(.........................................................)

**៤.៥ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារគ្រោះរាំងស្ងួត ឬ ខ្វះខាតទឹក ដែរ ឬ ទេក្នុងឆ្នាំ ២០១៨ កន្លងមក?**

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៦)*

ក. ខូចខាតដំណាំកសិកម្ម ☐

ខ. ប៉ះពាល់ដល់សត្វពាហនៈ ☐

គ. ខ្វះទឹកប្រើប្រាស់ក្នុងគ្រួសារ ☐

ឃ. ផ្សេងៗសូមបញ្ជាក់(.........................................................) ☐

**៤.៦ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារបាក់ច្រាំង ទន្លេ បឹង ស្ទឹង ព្រែក ក្នុងឆ្នាំ ២០១៨ កន្លងមកដែរ ឬ ទេ?**

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៥)*

ក. បាត់បង់ផ្ទះសម្បែង ☐

ខ. បាត់បង់អាយុជីវិត ☐

គ. ផ្សេងៗសូមបញ្ជាក់(.........................................................) ☐

៥. ការប្រែប្រួលអាកាសធាតុ

៥.១ តើក្នុងឆ្នាំ ២០១៨ កន្លងមក ស្ថានភាពទឹកភ្លៀងយ៉ាងដូចម្ដេចដែរនៅក្នុងភូមិ?

ក. ទៀងទាត់ ☐

ខ. មិនទៀងទាត់ ☐

គ. ទៀងទាត់ខ្លះ មិនទៀងទាត់ខ្លះ ☐

៥.២ តើសីតុណ្ហភាពក្នុងឆ្នាំ ២០១៨ កន្លងមក មានលក្ខណៈយ៉ាងដូចម្ដេចដែរនៅក្នុងភូមិ?

ក. ក្ដៅខ្លាំង ☐

ខ. ត្រជាក់ខ្លាំង ☐

គ. ក្ដៅល្មម ☐

ឃ. ត្រជាក់ល្មម ☐



បែបបទចេញពីប្រទេស
DEPARTURE



